# បេតិកភណ្ឌ មនុស្ស និងធម្មជាតិ



បង្រៀនដោយសាស្ត្រាចារ្យ
សេង ពិសិដ្ឋ
រៀបរៀងដោយនិស្សិត
ចេង ប៊ុនហេង
លី សំណាង
ឡូ កាំកង

# មាតិកា


អង្គរវត្ត ( នគរវត្ត ) ........ 3
ភ្នំបាក់ខែង ........ 11
អង្គរធំ ( នគរធំ ) ........ 15
ប្រាសាទបាយ័ន ........ 19
ប្រាសាទបាពួន ........ 23
ប្រាសាទបាពួន ........ 25
វិមានអាកាស ........ 27
ទីលានស្ដេចគម្លង់ ........ 29
ទេពប្រណម្យ ........ 31
ព្រះបាលិលេ្លយ ........ 33
ព្រះពិធូរ ........ 35
ឃ្លាំង ........ 37
ប្រាសាទតាកែវ ........ 39
ប្រាសាទតាព្រហ្ម ........ 41
ប្រាសាទបន្ទាយក្ដី ........ 45
ស្រះស្រង់ ........ 49
ប្រាសាទក្រវាញ ........ 51
ប្រាសាទប្រែរូប ........ 53
ប្រាសាទតាសោម ........ 55
ប្រាសាទក្រោលគោ ........ 57
ប្រាសាទនាគព័ន្ធ ........ 59
ប្រាសាទព្រះខ័ន ........ 63



# អង្គរវត្ត

# អង្គរវត្ត(នគរវត្ត)

*អង្គរវត្តនេះ គេធ្វើឧទ្ទិស្សថ្វាយដល់សាសនាព្រះព្រាហ្មណ៍គឺថ្វាយដល់ព្រះវិស្ណុ អង្គរវត្តនោះ គេមើលពីចម្ងាយទៅឃើញកំពូលមានសណ្ឋានដូចភ្នំសុមេរុ នៅជុំវិញអង្គរវត្តមានស្រះមានទឹកដក់នៅជានិច្ច ស្រះនោះគេរៀបចំថ្មជាថ្នាក់ៗ ដូចជាជណ្តើរសម្រាប់ចូលទៅក្នុងស្រះ តរពីស្រះទៅមានកំផែងព័ទ្ធជុំវិញ នៅកំប្លែងមានទ្វារសម្រាប់ចេញចូល គ្រប់ទិសទាំង៤តែទ្វារធំនៅខាងលិច មានផ្លូវថ្នល់ខាងក្រៅឆ្លងកាត់ស្រះទៅរហូតដល់ទៅទ្វារធំនោះនៅកំផែងទិសខាងលិចមានផ្លូវថ្នល់ខាងក្រៅឆ្លងកាត់ស្រះទៅរហូតដល់ទៅទ្វារធំនោះ នៅកំផែងទិសខាងលិច គេធ្វើមានសណ្ឋានជាពោងថែវ នៅពោងថែវនោះមានទ្វារ 5 គឺទ្វារ៣ នៅកណ្តាលទ្វារ៣ នៅទីបំផុតពោងថែវ ឯទ្វារ ៣ កណ្តាលជាទ្វារចេញចូលបានតែបររទេះសេះ ដំរី ចេញចូលមិនបានព្រោះទ្វាទាំងបីនោះជាទីមានផ្ទៃខ្ពស់ សុទ្ធតែមានជណ្តើរឡើងទៅឯទ្វារ២នៅទីបំផុតពោងថែវនោះនិងបរទេសសេះ ដំរី ចេញចូលបាន ព្រោះទ្វារនោះមានផ្ទៃខាងក្រោមរាបស្មើនិងផែនដី ឯត្រង់កន្លែងទ្វារកណ្តាលទាំង ៣ សុទ្ធតែមានកំពូលខ្ពស់ឡើងជាតួប្រាសាទតែត្រង់ទ្វារ១កណ្តាលនោះមានកម្ពស់ខ្ពស់ជាងកំពូលទ្វារទាំង២ដែលនៅសងខាង សព្វថ្ងៃនេះគេដើរចេញចូលតែតាមផ្លូវកណ្តាលធំព្រោះវានោះមានជណ្តើរចុះឡើងចំត្រង់ផ្លូវថ្មដែលភ្ជាប់ពីផ្លូវថ្នល់ខាងក្រៅទៅ ឯទ្វារ២សងខាងនោះគេមិនសូវចេញចូលទេព្រោះជណ្តើរចុះឡើងខុសពីផ្លូវនោះហើយមានទាំងរូបព្រះនារាយណ៍មួយៗ នៅត្រង់កណ្តាលទ្វារទាំង២នោះផង។ ពោងថែវនោះមានបង្អួចជាច្រើនតែអត់មានសន្ទឹកបើកចេញចូលទេ មានតែចម្រឹងដើងទៀននៅត្រង់រង្វង់បង្អួចទាំងនោះឃើញមានក្បាច់ចម្លាក់ជាច្រើនតែក្បាច់ចម្លាក់នោះរាក់ៗស្តើងៗអ្នកខ្លះយល់ថាក្បាច់ទាំងនោះ មានទំនងភាពប្រហែល ដូចជាក្បាច់របស់ចិន នៅទីពោងថែវនោះមានក្បាច់ចម្លាក់ និងរូបចម្លាក់ជាច្រើនទេរូបចម្លាក់ទាំងនោះសុទ្ធតែជារូបចំណែកខាងក្រោមសាសនាព្រាហ្មណ៍។*

*កំផែងតរពីពោងថែវនោះទៅ គេធ្វើដោយថ្មបាយក្រៀមជុំវិញ វៀរលែងតែត្រង់កន្លែងទ្វារទាំង៣ទិស គឺខាងកើត ខាងត្បូង ខាងជើង គេធ្វើដោយថ្មពណ៌ប្រផេះ នៅត្រង់ទ្វារទាំង ៣ នោះក៏សុទ្ធតែមានដំបូលខ្ពស់បន្តិចៗ តែមិនមានកំពូលខ្ពស់ជាតួប្រាសាទដូចជាទ្វារធំខាងឯលិចទេ។*



*ប្រាសាទអង្គរវត្តពីស្រះឈូកខាងជើង*

លុះដល់ចេញផុតពីរោងថែវតាមទ្វារខាងលិច ចុះជណ្តើរ ២ទៅ៥ កាំត្រូវដើរតាមផ្លូវថ្មនោះ មានផ្ទៃខ្ពស់ពីផែនដីហើយមានរូបនាគថ្មទៅកាន់ដៃទាំងសងខាងផ្លូវ ដែលបន្តិចទៅនឹងឃើញបណ្ណាល័យ២នៅសងខាងផ្លូវ តែបណ្ណាល័យនោះសព្វថ្ងៃនេះបាក់បែកអស់ទៅហើយក្បាច់ចម្លាក់នៅបណ្ណាល័យនោះក៏របេះរបកនឹងរលុបអស់ជាច្រើន លុះដើរបន្តិចទៅទៀតនឹងឃើញស្រះ២តូចៗនៅសងខាងផ្លូវនោះ ដែលតរពីនោះតែបន្តិចទៅ នឹងដោយទៅទីលានដីដែលជាទីទ្រប្រាសាទអង្គរវត្ត ផ្លូវថ្មនិងទីលានដីនោះមានផ្ទៃស្មើគ្នា ទីលានដីនោះមានរូបនាគថ្មជាប្រកាន់ដៃជុំវិញ ហើយមានជណ្តើរចុះទៅគ្រប់ទិស។

+ប្រាសាទអង្គរវត្តនោះមានជាន់៣

ជាន់ទី១គេធ្វើជារោងថែវមានដំបូលព័ទ្ធជុំវិញនៅត្រង់ជ្រុងរោងថែវទាំង៤ទិសមានកំពូលខ្ពស់បន្តិចឡើងមានសណ្ឋានដូចជាប៉ម នៅមុខទ្វារខាងលិច មានទីផ្ទៃថ្មជាយ៉ឥតដំបូលជាប់តពីរោងថែវនោះ


ជ្រុងមួយនៅក្នុងប្រាសាទ


ទិដ្ឋភាពអង្គរវត្តពីលើអាកាស

មក មានជណ្តើរឡើងពីខាងលិច ខាងជើង ខាងត្បូងនៅសងខាងទីយ៉នោះមានរូបនាគថ្មជាប្រកាន់ដៃ លុះដើរតាមទីយ៉ថ្មនោះបន្តិចទៅ ក៏ចូលទៅក្នុងទ្វាររោងថែវ ត្រង់កន្លែងទ្វារនោះ គេធ្វើជាតួប្រសាទបន្តិចខាងលើហើយមានដំបូលយ៉ចេញមកហើយខាងលិច នៅហោជាងដំបូលយ៉នោះ មានក្បាច់ចម្លាក់ខាងសាសនាព្រាហ្មណ៍ លុះដើរចូលទៅកណ្តាលរោងថែវ ហើយដើរបែទៅតាមរោងថែវខាងស្តាំនឹងឃើញជញ្ជាំងនៅខាងឆ្វេង នៅទីជញ្ជាំងនោះឃើញមានរូបចម្លាក់រំលេចជារឿងរ៉ាវនិងសិលាចារឹក គឺអក្សរដែលឆ្លាក់និងថ្មជាច្រើន នៅជុំវិញជរាបមកដល់ជញ្ជាំងទល់នឹងទ្វារខាងលិចហើយរឿងរ៉ាវនៅសិលាចារឹកនោះ ដូចសេចក្តីដែលពណ៌នាដោយសង្ខេបតទៅនេះ។

នៅជញ្ជាំងខាងលិចប៉ែកខាងស្តាំ ឃើញរឿងមហាភារត ត្រង់ចម្បាំងបណ្ឌវនឹងកោរវ(រឿងនេះជារឿងចម្បាំងធំ១ ក្នុងរឿងព្រេងក្នុងស្រុកឥណ្ឌា រឿងនេះមានតែក្នុងអក្សរសំស្ក្រឹតឯក្នុងអក្សរខ្មែរមិនមាន)។

នៅជ្រុងថែវទិសនិរតី ត្រង់ជ្រុងនេះចែកជា៤ដាន គឺបានខាងជើង ខាងត្បូង ខាងលិចខាងកើត ត្រង់ដានជញ្ជាំងខាងកើត ឃើញរឿងក្រិស្នាដែលកើតពីវិស្ណុ ជាទេវតាឃ្វាលគោ កាលទ្រភ្នំគោវធន៌ដើម្បីនឹងបាំងទឹកភ្លៀងកុំឲ្យទទឹកអស់ទាំងហ្វូគោ ជញ្ជាំងខាងលិចត្រង់លើបង្អួចខឃើញរឿងកូរសមុទ្រទឹកដោះ ត្រង់ទេវតានឹងអសុរទាញនាគ ត្រង់ដែនខាងត្បូងជញ្ជាំងខាងកើតភាគខាងលើ ឃើញរឿងរាមាយណមត្រង់ពាលីនិងសុគ្រីពច្បាំងគ្នា ភាគខាងក្រោមឃើញពពាលីស្លាប់ជញ្ជាំងខាងលិចភាគខាងលើ ឃើញរូបព្រះឥសូរដំណែងខ្លួនជាឥសីប្រដាប់ដោយផ្កាំភាគខាងក្រោមឃើញទ្វារឈ្មោះ កាមជាអ្នកបណ្តាលឲ្យកើតឡើងនូវសេចក្តីជម្រេក កំពុងតែបាញ់តម្រង់ទៅព្រះឥសូរៗ ក៏ក្រឡេកមើលមកទេវតាឈ្មោះ កាម ដោយភ្នែកដែលមាននៅត្រង់ថ្ងាស់ ទេវតាឈ្មោះ កាម ក៏ឆេះរលាយទៅជាផេះ ត្រង់ដានខាងលិចជញ្ជាំង ខាងត្បូងឃើញរូបព្រះឥសូរអង្គុយលើភ្នំ ហើយឃើញរាពណ៍មានដៃ ២០ ក្បាលកំពុងតែធ្វើភ្នំឲ្យរំជួលដោយសេចក្តី ឈ្នានីសដល់ព្រះឥសូរជញ្ជាំងខាងជើងឃើញរឿងមិនប្រាកដជា

រឿងអ្វី ត្រង់ដានខាងកើត នៅទីខាងលើទ្វារឃើញរូបព្រះនារាយណ៍មានដៃ៤ហើយឃើញរូបអ្នកដែលយករបស់ទៅបូជា។

នៅជញ្ជាំងខាងត្បូងប៉ែកខាងឆ្វេង ឃើញរឿងរ៉ាវពង្សាវតារខ្មែរនិងសិលាចារឹកប្រាប់ពីរឿងដែលមាននៅទីនោះ សិលាចារឹកប្រាប់ថាមនុស្ស ដែលជាមេផានាយនិងបណ្ឌិតទាំងឡាយយកដង្វាយទៅថ្វាយស្តេច តរពីនោះបន្តិចទៅឃើញសិលាចារឹក១ទៀតប្រាប់ថាស្តេចបរមវិស្ណុលោកនៅលើភ្នំ សិវបទត្រាស់បង្គាប់ឱ្យប្រមូលពួកកងទ័ព តរទៅពីនេះទៅទៀតឃើញរូបជិះលើដំរីច្រើន រូបទាំងនោះសុទ្ធតែជារូបមន្ត្រី កាត់សក់មានភាពទំនងដូចជាសក់ដែលខ្មែរកាត់សព្វថ្ងៃនេះហើយឃើញមានសិលាចារឹកជាច្រើនប្រាប់ឈ្មោះមន្ត្រីទាំងនោះឃើញរូប១ទៀតឈរលើដំរីរូបនោះគឺជារូបស្តេច ព្រោះឃើញសិលាចារឹកនៅជិតរូបនោះប្រាប់ថាបានជាស្តេច ឈ្មោះស្រីជ័យវរ្ម័ន នៅក្នុងកងទ័ព្យទាំងនោះឃើញមានរូបព្រាហ្មណ៍ជាច្រើន សុទ្ធតែមានផ្នួងសក់ព័ទ្ធធ្លាក់ដោយអង្កាំ ឃើញរូបព្រាហ្មណ៍ជិះលើអង្រ្រឹងរូបព្រាហ្មណ៍នោះប្រហែលមានសក្តិធំជាងគេព្រាហ្មណ៍ទាំងនោះសុទ្ធតែកាន់គ្រឿងប្រដាប់របស់ពួកព្រាហ្មណ៍ ហើយឃើញរូបព្រាហ្មណ៍ខ្វះសែងពេងភ្លើង តរពីនោះទៀតឃើញមានសិលាចារឹកមួយទៀតប្រាប់ថានោះជាស្យាមកុត។

នៅជញ្ជាំងខាងត្បូងប៉ែកខាងស្តាំ ឃើញចម្លាក់រឿងនរកនិងស្ថានសួគ៌ហើយនិងសិលាចារឹកជាច្រើន សិលាចារឹកប្រាប់ថានេះជាផ្លូវខាងលើគឺស្ថានសួគ៌សិលាចារឹក ទៀតប្រាប់ថានេះជាផ្លូវខាងក្រោមគឺនរក រូបចម្លាក់ត្រង់នេះមាន ៣ ផ្នែកគឺផ្នែកខាងលើនិយាយពីស្ថានសួគ៌ផ្នែកខាងក្រោមនិយាយពីឋាននរក ផ្នែកកណ្តាលនិយាយសុទ្ធតែរូបគ្រុឌ។



ទិដ្ឋភាពអង្គរវត្តពីលើអាកាស

កាលបានមើលត្រង់ផ្នែកខាងក្រោម ដើរតរទៅនឹងឃើញសិលាចារិកប្រាប់ថានេះជាព្រះយមឃើញរកព្រះយមនោះមានដៃ ១៨ ហើយជិះលើគោ តរពីនោះទៅឃើញសិលាចារឹក១ទៀតប្រាប់ថានេះជាព្រះធម៌ជាធំខាងការជំនុំជម្រះ នៅជិតនោះឃើញរូបចិត្រគុប្តជាក្រឡាបញ្ជីនៃព្រះយម កំពុងតែលើកដំបូងចង្អុលទៅអស់ពួកសត្វនរក តែសិលាចារិកនោះឥឡូវនេះរលុបមិនឃើញច្បាស់ តពីនោះទៅទៀតឃើញមានសិលាចារឹក ជាច្រើនប្រាប់ឈ្មោះស្ថាននរកផ្សេងៗនិងទោសរបស់អ្នកដែលទៅ

នរកនោះដូចជាសិលាចារឹកដែលបាននាំមកពោលខ្លះក្នុងខាងក្រោយនេះ។

សិលាចារឹកប្រាប់ថានរកឈ្មោះ អវិចិ សម្រាប់អ្នកដែលមានទ្រព្យសម្បត្តិហើយប្រព្រិត្តធ្វើតែអំពើពិបាក។

សិលាចារឹកប្រាប់ថា នរកឈ្មោះក្រិមិនិចយ សម្រាប់អ្នកដែលប្រមាថមើលងាយ ឬតេះដៀលដល់ទេវតា ដល់ភ្លើងដ៏ប្រសើរដល់គ្រូអាចារ្យ ដាក់ដល់ពួកព្រាហ្មណ៍ ឬតេះដៀលមើលងាយដល់ព្រះធម៌ ដល់អ្នកបម្រើព្រះឥសូរឬដល់អ្នកដែលគួរគោរពមានមាតាបិតាជាដើម។

សិលាចារិកប្រាប់ថា នរកឈ្មោះវៃតរណីទនី សម្រាប់អ្នកដែលធ៏បំបាត់គេ លួចគេ។

តទៅឃើញមានសិលាចារិក១ទៀត តែមិនច្បាស់ត្រង់ឈ្មោះនរកឃើញតែតែសេចក្តី ថាសម្រាប់អ្នកដែលនិយាយមិនពិតឬមនុស្សដែលធ្វើជាបន្ទាល់ខុស។

សិលាចារិកប្រាប់ថា នរកឈ្មោះយុគ្មបវ៌តសម្រាប់មនុស្សដែលកាចប្រហើន ដែលសម្លាប់គេ។

សិលាចរិកប្រាប់ថា នរកឈ្មោះនិរុច្ឆ្វាស សម្រាប់មនុស្សដែលកាចសាហាវកាប់សម្លាប់អស់ទាំងស្រីអស់ទាំងក្មេងតូចៗ។

សិលាចារិកប្រាប់ថានរកឈ្មោះ ឧច្ឆ្វាស សម្រាប់អ្នកដែលប្រព្រឹត្តអំពើទុច្ចរិតនិងអ្នកដែលនិយាយដើមគេ និងអ្នកដែលបរិភោគនូវសាច់ជាអកប្បិយ គឺសាច់មិនគួរបរិភោគតាមលទ្ធិក្នុងសាសនាព្រាហ្មណ៍។

សិលាចារឹកប្រាប់ ថានរកឈ្មោះ ទ្រវត្រ្តបុ សម្រាប់អ្នកដែលធ្វើនូវអំពើអាក្រក់ដល់អ្នកដទៃនិងអ្នកដែលកំហែងយកដីយកផ្ទះយកទីលំនៅអ្នកដទៃ។

សិលាចារិកប្រាប់ថា នរកឈ្មោះ តប្តលាក្សាមយ សម្រាប់អ្នកណាដុតបំផ្លាញរបស់អ្នកដទៃ មានដុតផ្ទះជាដើម និងអ្នកដែលឱ្យថ្នាំបំពុលដល់អ្នកដទៃ។

សិលាចារិកប្រាប់ថា នរកឈ្មោះ អស្ថិភង្គ សម្រាប់អ្នកដែលធ្វើបង្ខូចបំផ្លាញរបស់អ្នកដទៃមានសួនច្បានិងផ្ទះជាដើម។

សិលាចារិកប្រាប់ថា នរកឈ្មោះ ក្រកច្ឆេទ សម្រាប់អ្នកដែលល្មោភស៊ី។

សិលាចារិកប្រាប់ថា នរកឈ្មោះ បូយបូណ៌ហ្រាទ សម្រាប់អ្នកដែលលួចស្រា លួចប្រពន្ធគេ។

សិលាចារិកប្រាប់ថា នរកឈ្មោះអស្រើក្បូណ៌ហ្រាទ សម្រាប់អ្នកដែលលួចសាច់ លួចប្រពន្ធអ្នកដទៃ នឹងលួចប្រពន្ធអ្នកបេះដឹងឬអ្នកប្រាជ្ញ។

សិលាចារិកប្រាប់ថា នរកឈ្មោះ មេទោហ្រាទ សម្រាប់ស្ត្រីដែលមានសេចក្តីទុច្ចចរិត។

ឃើញសិលាចារឹក១ទៀតរលប់មើលមិនច្បាស់តែនៅជិតសិលាចារិកនោះឃើញមនុស្សមានពោះធំគេកំពុងតែវាយ។

សិលាចារឹកប្រាប់ថា នរកឈ្មោះ តិក្សាយស្កន្ធ សម្រាប់មានដៃរលួចស្រូវលក់អង្ករគេ។

តពីនេះទៅទៀតឃើញមានសិលាចារិកជាច្រើននិយាយពីនរកសម្រាប់អ្នកដែលកាប់ដើមឈើ អ្នកលួចដំរីអ្នកលួចផ្កាក្នុងសួនច្បារព្រះឥសូរ។ល។ល បើករួបរួមស្ថាននរកនិងស្ថានសួគ៌ទាំងអស់ស្ថានរូបមាន ៣២ ពីស្ថានសួគ៌មាន ៣៧។


ទិដ្ឋភាពអង្គរវត្តនាពេលថ្ងៃលិច


ទិដ្ឋភាពអង្គរវត្តនាពេលថ្ងៃត្រង់


ទិដ្ឋភាពអង្គរវត្តនាពេលថ្ងៃរះ



*ទិដ្ឋភាពអង្គរវត្តពីបុរាណកាល*

៥ នៅជញ្ជាំងខាងកើត ប៉ែកខាងត្បូង ឃើញរឿងមាយាយត្រង់កណ្ដាលនិយាយអំពីកូរសមុទ្រទឹកដោះក្នុងរឿងនេះឃើញរូបនាគធំវែងស្មើរតែនឹងផុតជញ្ជាំងប្រវែង៤៩ម៉ែត្រហើយឃើញទេវតានិងអសុរឃើញទាញនាគនោះ ទេវតាទាញខាងក្បាលអសុរទាញខាងកន្ទុយនៅត្រង់កណ្ដាលឃើញរូបព្រះនារាយណ៍មានដៃ៤ នៅផ្ទាប់នឹងភ្នំមន្ទរៗ នោះស្ថិតនៅលើអណ្ដើក។

៦នៅជញ្ជាំងខាងកើតប៉ែកខាងស្ដាំឃើញរឿងចម្បាំងនៃទេវតានិងអសុរៈ នៅកណ្ដាលចម្បាំងនោះឃើញ រូបវិស្ណុជិះលើគ្រុឌ។

៧នៅជញ្ជាំងខាងជើងប៉ែកខាងត្បូង ឃើញរឿងមហាភារត។

៨នៅជញ្ជាំងខាងជើងប៉ែកខាងស្ដាំ ឃើញកុវេរជិះលើស្នាយក្ស ទេវតាឈ្មោះស្កន្ទជិះលើក្ងោកព្រះឥន្ទ្រជិះលើដំរីអៃរាវណ វិស្ណុជិះលើគ្រុឌ យមជិះលើរថទិមដោយគោ សិវព្រហ្មជិះលើហង្ស សូរ្យនៅមណ្ឌល វរុណជិះលើនាគ។

៩នៅជ្រុងថែវទិសពាយព្យ ត្រង់ជ្រុងនេះចែកជា៤ដានគឺដាន១ខាងកើត១ខាងលិច១ខាងជើង១ខាងត្បូងត្រង់ដានខាងកើតជញ្ជាំងខាងត្បូង ឃើញរូបវិស្ណុជិះលើគ្រុឌឃើញវិស្ណុកាន់មន្ទ ដើម្បីនឹងកូរទឹកសមុទ្រ ជញ្ជាំងខាងជើងភាគខាងលើ ឃើញព្រះនាយណ៍ជិះលើនាគ ព្រះខាងក្រោមឃើញទេវតាទាំង៩ខាងសាសនាព្រាហ្មណ៍ គឺសូរ្យជិះលើរថ កូវេរជាទេវតាខាងភោគសម្បទ ជិះលើយក្ស ព្រាហ្មណ៍ជិះលើហង្ស ស្កន្ទជិះលើគោក្ងោក ទេវតា១ទៀតជិះលើសេះ ព្រះឥន្ទ្រជិះលើដំរី ព្រះយមជិះលើគោ សិវជិះលើគោឧសភ ទេវតា១ទៀតជិះលើសីហ ត្រង់ដានខាងលិចជញ្ជាំងខាងត្បូង ឃើញរឿងរាយណ ត្រង់សេចក្ដីកាលហណុមាន យកចិញ្ចៀនទៅថ្វាយនាងសិតា នៅកោះលង្កា ជញ្ជាំងខាងជើងឃើញរឿងមិនប្រាកដ ត្រង់ដានខាងជើងជញ្ជាំងខាងលិច ឃើញរឿងរាមយណ កាលព្រះរាមឲ្យនាងសិតាចូលភ្លើង ជញ្ជាំងខាងកើតឃើញរឿងមិនប្រាកដត្រង់ដានខាងត្បូងជញ្ជាំងខាងកើតឃើញរឿងរាមាយណកាលព្រះរាមថ្ងៃងសរប្រឡងដើម្បីនឹងយកនាងសិតាជញ្ជាំងខាងលិចឃើញរឿងមិនប្រាកដ។

១០ នៅជញ្ជាំងខាងលិច ប៉ែកខាងត្បូង ឃើញរឿងចម្បាំងនៃព្រះរាមនិងរាពណ៍។

*កាលបើមើលរូបចម្លាក់រម្ទេចនិយាយពីរឿងរ៉ាវនៅជញ្ជាំងរោងថែវជាន់ទី1 សព្វគ្រប់ហើយ ត្រូវទៅតាមផ្លូវទ្វារខាងលិចត្រង់ចំពោះទៅជណ្ដើរសម្រាប់ឡើងទៅកាន់រោងថែវក្នុងជាន់ទី ២។*

*ជាន់ទី ២ មានទំហំតូចជាងជាន់ទី ១តែខ្ពស់ជាងហើយមានរោងថែវព័ទ្ធជុំវិញចំណែកទិសខាងលិចត្រង់ចន្លោះរោងថែវត្រូវជាន់ទី1 និងរោងថែវជាន់ទី2 មានរោងថែវប្រទាក់គ្នា ខ្វាត់ខ្វែងជាក្រឡាឈើត្រង់ គឺរោងថែវនោះមានប៉ុ៣ជួរតរ ជាប់ពីរោងថែវជាន់ទី ១ ទៅរោងថែវជាន់ទី 2 កាលទៅរោងថែវជាន់ទី ១ តាមទ្វារធំកណ្ដាលនឹងទៅតាមជណ្ដើរកណ្ដាលចំនួន ៦ទៅ៧ កាំទៅកាន់រោងថែវកណ្ដាលបើទៅតាមទ្វារទាំងសងខាងនិងឡើងទៅតាមជណ្ដើរទាំងសងខាង ទៅកាន់រោងថែវទាំងសងខាងមានរោងថែវ១ទៀតការទៅទទឹងចំពាក់កណ្ដាលជាប់ពីរោងថែវខាងត្បូងទៅរោងថែវខាងជើង ក្នុងចន្លោះទាំង៤នៃរោងថែវនោះមានស្រះតូចៗ ៤។ ក្នុងរោងថែវខាងត្បូងឃើញមានព្រះពុទ្ធរូបជាច្រើនអង្គ ជាព្រះពុទ្ធរូបសាងតាមបែបខាងមហាយានខ្លះ ហីនយានខ្លះតែដែល គេយកមកដំកល់ក្នុងទីនោះក្នុងកាលផ្សេងៗ គ្នាខ្លះយកមកមុនខ្លះយកមកក្រោយកាលមើលចេញពីទ្វារផត្រូវខាងជើងនិងខាងត្បូងទៅនឹងខាងបណ្ណាល័យ២នៅលើទីផ្ទៃខាងក្រោមដែលទ្រជាន់ទី2 ដែលនឹងឡើងទៅរោងថែវជាន់ទី២នោះមានជណ្ដើរ ១៤សម្រាប់ឡើងទៅនឹងឡើងទៅតាមជណ្ដើរណា១ក៏បាន តែបើទៅតាមផ្លូវខាងលិច ត្រូវដើរទៅតាមរោងថែវកណ្ដាល ហើយឡើងទៅតាមជណ្ដើរកណ្ដាលចំនួន១៧ទៅ១៨ កាំ ក៏ដល់ទៅលើទីផ្ទៃរោងថែវជាន់ទី ២នៅក្នុងរោងថែវនេះ ឃើញមានរូបព្រះនារាយណ៍មានដៃ 4 នៅច្រកផ្លូវខាងលិច ឃើញរូបព្រះនារាយណ៍ទី ២ ទៀតនៅត្រង់ទ្វាររោងថែវខាងត្បូង ព្រះនារាយណ៍មានដៃ៤ត្រង់ពាក់កណ្ដាលខ្លួនខាងក្រោមឃើញទ្រង់ជារូបអណ្ដើក ហើយឃើញមានទាំងព្រះពុទ្ធជារូបច្រើនអង្គ ព្រះពុទ្ធរូបទាំងនោះ គេទើបនឹងយកមកតំកល់ទុកក្នុងកាលជាខាងក្រោយទេ។*



*មាត់ទឹកនៅប្រាសាទ*

*កាលដែលចូលផុតពីជាន់ទី ២ តាមទ្វាររោងថែវខាងលិចក៏ទៅដល់ទីផ្ទៃខាងក្រោមដែលត្រូវជាន់ទី ៣។*

*នៅផ្ទៃខាងក្រោមជាន់ទី ៣ មានផ្លូវថ្មដូចជាស្ពានតរជាប់ពីរោងថែវជាន់ទី 2 មកផ្លូវថ្មនោះភ្ជាប់ទៅនឹងជណ្ដើរខ្ពស់ដែលនឹងឡើងទៅកាន់ជាន់ទី ៣ ហើយមានផ្លូវ១ទៀតកាត់ពាក់កណ្ដាលផ្លូវនោះទៅខាងកើតនិងខាងត្បូង ជាប់ទៅនឹងប្រាសាទតូចៗនៅខាងជើង១ខាងត្បូង១ប្រាសាទទាំង២នោះឥឡូវនេះបាក់បែកអស់ហើយ។*

*ជាន់ទី៣នេះមានទំហំតូចជាងជាន់ទី ២ តែខ្ពស់ជាងជាន់ទី២ ហើយមានជណ្ដើរសម្រាប់ឡើងទៅ ១២ គឺជណ្ដើរ៣ខាងលិច៣ ខាងកើត៣ ខាងជើង៣ ខាងត្បូង៣ បើឡើងទៅលើជាន់ទី3 ត្រូវឡើងតាមជណ្ដើរកណ្ដាលខាងលិច ព្រោះជណ្ដើរនោះមិនសូវចោតពេកឡើងទៅចំនួន ៣៥ កាំក៏ ដល់ទៅខាងលើជាន់ទី ៣នៅលើជាន់ទី ៣នោះមានប្រាសាទ១នៅត្រង់កណ្ដាលមានរោងថែវព័ទ្ធជុំវិញ ហើយមានរោងថែវជាប់ពីថែវខាងលិច ខាងកើត ខាងត្បូង ខាងជើង តរទៅនិងប្រាសាទកណ្ដាល ហើយមាន*

ប្រាសាទមួយៗ នៅគ្រប់ជ្រុង រង់ថែវទាំង៤ តែប្រាសាទជ្រុងទាំង៤នោះ តូចនិងទាបជាងប្រាសាទកណ្ដាល កំពូលប្រាសាទទាំង៥នោះហើយដែល យើងបានពោលខាងដើមថាមានសណ្ឋានដូចភ្នំព្រះសុមេរុ ក្នុង ចន្លោះទាំង៤នៃរោងថែវនោះមានស្រះតូចៗ ៤ កាលចូលទៅដល់ប្រាសាទកណ្ដាលនិងឃើញមាន ព្រះពុទ្ធរូបឈរ1ព្រះអង្គមានអគ្គសាវកទាំង2កំពុងនមស្សការ ជាព្រះរូបគេឆ្លាក់បន្ទំនៅនឹងផែនថ្មនៅ ទីខាងមុខព្រះពុទ្ធរូបឈរនោះឃើញមានព្រះពុទ្ធរូបច្រើនព្រះអង្គល្អខ្លះខ្លះដែលឃើញមានយ៉ាងនេះ តែ៣ទិសគឺខាងលិច ខាងកើត ខាងជើង ឯខាងត្បូងមិនឃើញមានអ្វីឃើញតែចន្លោះរង្វង់ទ្វារទទេ។



*ទិដ្ឋភាពអង្គរវត្តនាពេលថ្ងៃលិច*

យើងចូលចិត្តថាព្រះពុទ្ធរូប ដែលគេឆ្លាប់ភ្ជាប់នឹងផែនថ្មក្នុងប្រាសាទកណ្ដាលនោះគេទើបនឹង ធ្វើកាលជាខាងក្រោយមិនមែនគេធ្វើដូចនោះតាំងពីក្នុងជាន់ធ្វើអង្គរនោះទេកាលពីដើមគេធ្វើរូប ព្រះវិស្ណុតម្កល់ទុកក្នុងប្រាសាទកណ្ដាលនោះព្រោះស្ដេចដែលកសាងពីអង្គរវត្តនោះជាអ្នកកាន់សាសនា ព្រាហ្មណ៍ តែដល់មកខាងក្រោយ មានពួកអ្នកកាន់ព្រះពុទ្ធសាសនាខាងហីនយានមកនៅគ្រប់គ្រង រក្សាទីនោះ ក៏លើកយករូបព្រះវិស្ណុនោះចេញហើយយកថ្មទៅដាក់ស្ទះត្រង់កន្លែងទ្វារទាំង៤ទិសទើប ឆ្លាក់ព្រះពុទ្ធរូបឈរនិងផែនថ្មនោះគ្រប់ទ្វាទាំង៤ទិសឯទិសខាងត្បូងសព្វថ្ងៃនេះមិនឃើញមាន ព្រោះ គេទើបនឹងរើចេញខាងក្រោយទេ។

ប្រាសាទអង្គរវត្ត កាលណាបើឡើងទៅដល់ជាន់ខាងលើហើយក្រឡេកមើលទៅខាងក្រោមឃើញ ល្អណាតែបើមើលក្នុងពេលដែលព្រះអាទិត្យរៀបហ្នឹងអស្ដង្គត ក៏រឹតតែឃើញល្អគួរតែចង់ឲ្យមើលណា ព្រោះក្រឡេកមើលសព្វៗទៅក៏បណ្ដាលឱ្យកើតឡើងនូវសេចក្ដីស្រងូតស្រងាត់ក្នុងចិត្ត។

លុះដល់ត្រឡប់ចុះមកវិញហើយក្រឡេកមើលក្បាច់ចម្លាក់នៅជញ្ជាំងនៅសសរ នៅក្លោងទ្វារ ហើយនិងបង្អួចតាមផ្លូវដើរចុះមក ក៏នឹងឃើញក្បាច់ចម្លាក់ទាំងនោះល្អណាស់គួរឱ្យចង់មើលគួរអោយ ស្ងើចក្នុងចិត្តដោយក្រៃលែង(សូមឱ្យអស់លោកអ្នកដែលទៅមើលអង្គរ កាលបើត្រឡប់ចូលមកវិញ សូមឲ្យក្រឡេកមើលទៅខាងក្រោយវិញកុំខកខានឡើយ)។

លុះចុះមកដល់ជាន់ទី១ត្រង់ទីយ៉ៃនៅមុខទ្វារខាងលិចនឹងបានឃើញនូវវត្តលោកសំយគគណម មហានិកាយ២វត្ត១នៅខាងជើងវត្ត វត្ត ១ នៅខាងត្បូង វត្តទាំងពីរនោះគេទើបនឹង កសាងក្នុងកាលជា ខាងក្រោយ មិនមែនកសាងជំណាលគ្នានិងអង្គរវត្តនោះទេ។



# ភ្នំបាក់ខែង

# ភ្នំបាក់ខែង

*ដែលនឹងទៅពីអង្គរវត្តទៅភ្នំបាក់ខែងនោះ ត្រូវទៅតាមផ្លូវថ្នល់ត្រូវទៅខាងជើងចំពោះទៅអង្គរធំ ផ្លូវនោះល្អត្រជាក់ស្រួលដោយម្លប់ឈើនៅសងខាងផ្លូវនៅតែ ៤០០ ម៉ែត្រទៀតនឹងដល់ទៅទ្វារ អង្គរធំខាងត្បូងនិងឃើញភ្នំបាក់ខែងនោះស្ថិតនៅជាខាងលិចផ្លូវ។*



*ព្រះពុទ្ធដែលនៅលើខឿន*

*ភ្នំនេះកាលពីដើមឈ្មោះថាឥន្ទ្រាទ្រី  គឺភ្នំរបស់ព្រះឥន្ទ្រឬភ្នំជាធំ ដល់មកក្នុងរាជស្ដេចឈ្មោះ យសោវរម័ន គេបានសាងតួប្រាង្គណ៍និងប្រាសាទនៅលើភ្នំនោះ ដើម្បីឧទ្ទិសថ្វាយដល់ព្រះឥសូរ ទើបឲ្យឈ្មោះទីនោះថា យសោធរេស្វរ។*

*ដែលនឹងឡើងទៅលើភ្នំនោះត្រូវទៅដោយផ្លូវ២យ៉ាងផ្លូវ១គឺផ្លូវចោតពិបាកឡើងទៅណាស់ ផ្លូវនោះកាលពីដើមវាជាផ្លូវល្អមានកាំជណ្ដើរសម្រាប់ឡើងទៅស្រួល តែឥឡូវនេះបាក់បែកខូចអស់ហើយ នៅតែដីនិងថ្ម ឃើញនៅសល់តែរូបសត្វសីហ ២ នៅ ត្រង់ជណ្ដើរខាងក្រោមផ្លូវ១ទៀតជាផ្លូវជ្រាល គេអាចឡើងទៅដោយដើងឬបរសេះដំរីឡើងទៅក៏បាន ផ្លូវនោះគេធ្វើបត់ចុះបត់ឡើង ទើបនឹងធ្វើក្នុងកាលជាខាងក្រោយ។*



*ទិដ្ឋភាពមើលពីក្រោម*



*ចំហៀងព្រះពុទ្ធបដិមា*

*កាលបើឡើងតាមផ្លូវចោតដល់ទៅខាងលើកំពូលភ្នំ ត្រូវដើរទៅតាមផ្លូវរៀបថ្មត្រង់ទៅខាងលិច នឹងឃើញសិលាលិខិតគឺលិខិតព្រះឥសូរ២ទៅ៣ នៅនាផ្លូវនោះ ដើរតពីនោះទៅនឹងឃើញប្រាសាទពីតូចៗ ធ្វើដោយថ្មតែអត់មានក្បាច់ចម្លាក់អ្វីទេ ដើរបន្តិចទៅទៀតនឹងដល់ទីប្រាង្គណ៍នោះមាន៥ថ្នាក់មានជណ្ដើរឡើងទៅគ្រប់ថ្នាក់ នៅកណ្ដាលជណ្ដើរសុទ្ធតែមានរូបសីហហើយមានប្រាសាទតូចជាច្រើននៅគ្រប់ថ្នាក់ នៅទីខាងលើប្រាង្គណ៍មានប្រាសាទ៥ប្រាសាទ១នៅត្រង់កណ្ដាលប្រាសាទតូច ៤ នៅគ្រប់ជ្រុងទាំង៤ទិស ឯប្រាសាទកណ្ដាលនោះគេទើបនឹងឃើញក្នុងរវាង២ឆ្នាំមុននេះទេ ព្រោះកាលពីដើមប្រាសាទនោះមានថ្មស្រោបជុំវិញ បិទជិតតាំងពីខាងក្រោមរហូតដល់ខាងលើថ្មដែលស្រោបនឹងមានសណ្ឋានជាបល្ល័ង្កព្រះ ហើយមានព្រះ ពុទ្ធរូបគេធ្វើតម្កល់លើថ្មនោះ តែមិនទាន់ស្រេចទើបនឹងបានត្រឹមព្រះភ្នែន ឯថ្មដែលស្រោបប្រាសាទនិងព្រះពុទ្ធរូបត្រឹមព្រះភ្នែននោះ ប្រហែលជាគេទើបនឹងធ្វើក្នុងរវាង ៤ទៅ៥ រយឆ្នាំមុននោះទេដឹង តែឥឡូវនេះគេរើសយកចេញអស់ហើយ នៅតែប្រាសាទកណ្ដាលៗ នោះក៏បាក់បែកជាច្រើន តែនៅឃើញមានក្បាច់ខាងក្រៅល្អណាស់ដែរ។*

*ភ្នំបាខែងនោះ ជាភ្នំគេដើរមើលលេងលើកំពូលសប្បាយណាស់ បើដើរមើលក្នុងវេលាដែលព្រះអាទិត្យ បើមើលលេងក្នុងវេលាដែលព្រះអាទិត្យ រៀបនឹងអស្ដង្គតនោះរឹតតែសប្បាយព្រោះឥតមានកំដៅព្រះអាទិត្យការបើឈរខាងលើភ្នំហើយ ក្រឡេកមើលទៅជុំវិញនឹងបានឃើញសព្វព្រៃព្រឹក្សាល្អមើលណាស់ ទាំងទីអង្គរវត្តក៏មើលទៅឃើញព្រោះភ្នំនោះខ្ពស់ជាងដើមឈើទាំងឡាយដែលមាននៅក្នុងទីនោះ។*

*កាលណារៀបនិងចុះពីភ្នំបាក់ខែងមកវិញ គួរទៅមើលស្នាមព្រះពុទ្ធបាទឬស្នាមព្រះបាទព្រះពុទ្ធដែលស្ថិតនៅខាងកើតទីប្រាង្គណ៍ ព្រះបាទនោះគួរឱ្យចង់មើលណាស់ព្រោះគេសាងបង្អួងចុះជម្រៅចំនួន ៥០ សង់ទីម៉ែត្របណ្ដោយចំនួន ២ ម៉ែត្រ ២០ សង់ទីម៉ែត្រហើយមានកុដិប្រកក្បឿងតូច១គ្របពីលើកុដិនោះ លោកសំឃយួនទើបនឹងធ្វើក្នុងកាលជាខាងក្រោយទេ។*

*លុះដល់ចុះពីភ្នំនោះមកវិញត្រូវទៅតាមផ្លូវដូចបាននិយាយពីខាងលើហើយ លុះទៅតាមផ្លូវនោះទៅ ក៏ដល់ទ្វារអង្គរធំខាងត្បូង។*



*នៅទិសខាងកើតនៅលើកំពូល*


ទិដ្ឋភាពនៅពេលល្ងាច


ចំហៀងព្រះពុទ្ធបដិមា



# អង្គរធំ

# អង្គរធំ( នគរធំ )

អង្គរធំចម្ងាយពីសៀមរាប ៧៩០០ ម៉ែត្រ ចម្ងាយពីអង្គរវត្ត ១៧០០ម៉ែត្រអង្គរធំដូចមានស្រះព័ទ្ធជុំវិញនៅកំផែងនោះមានទ្វារ ៥ គឺទ្វារទី ២ ទ្វារខាងកើត១ខាងត្បូង១ខាងលិច១ខាងជើងឯទ្វារ២ខាងកើតនៅទ្វារ១នៅចាំពាក់កណ្ដាលត្រង់ពីបាយ័នទៅហៅថាទ្វារខ្មោចទ្វារ១ទៀតនៅខាង



ខ្លោងទ្វារចូល

ទៀងខាងជើង ត្រង់ពីព្រះលានស្ដេចទៅហៅថាទ្វារជ័យដែរនឹងទៅតាមទ្វារមួយៗនោះត្រូវទៅតាមផ្លូវដែលធ្វងកាត់ស្រះចូលទៅរហូតដល់ទ្វារ ផ្លូវនោះមានរូបនាគថ្មលនៅសងខាងកន្ទុយបែរទៅខាងក្នុងក្បាលចេញមកខាងក្រៅរូបនាគម្ខាងមានរូបទេវតាជាច្រើន ដែលប្រដាប់ដោយមកុដចប់ទាញរូបនាគម្ខាងទៀតមានរូបអសុរជាច្រើនដែលមានមុខក្រញូវចាប់ទាញៗ

ផ្លូវដែលធ្វងកាត់ស្រះចូលទៅកាន់ទ្វាទាំងអស់ កាលពីដើមសុទ្ធតែមានរូបនាគនៅសងខាងហើយមានទេវតានិងអសុរចាប់ទាញដូចសេចក្ដីខាងលើនេះ តែសព្វថ្ងៃបាក់បែកអស់ហើយប៉ុន្តែគេរៀបចំជួសជុលធ្វើផ្លូវដែលទៅតាមទ្វារជ័យឲ្យមានរបៀបដូចពីដើមឡើងវិញ ឯទ្វាទាំង៥ នោះមានទំហំនិងសណ្ឋានដូចគ្នា មានកម្ពស់ជាង ៧ ម៉ែត្រទ្វារនោះឯងសុទ្ធតែមានក្បាច់ចម្លាក់ទាំងខាងក្នុងខាងក្រៅ ហើយមានរូបក្បាលដំរីនៅសងខាងត្រង់ជ្រុងទ្វារ ឯខាងលើទ្វារនោះប្រដាប់ដោយមុខ៤បែរទៅគ្រប់ទិសទាំង៤ៗ

| | | |
|---|---|---|
|  |  |  |
| ច្រកខាងលិច | ចំហៀងប្រាសាទ | ទេសភាពតាមដងផ្លូវ |

*ឯមុខទាំង៤ដែលនៅលើទ្វារនោះគេតែងចូលចិត្តផ្សេងៗគ្នា ខ្លះចូលចិត្តថាមុខព្រហ្ម ខ្លះថាមុខព្រះឥសូរ និងរកឲ្យប្រាកដមិនឃើញ តែឥឡូវនេះមានអ្នកប្រាជ្ញបារាំង ១ នាក់ឈ្មោះល្វីហ្វីណូត៍ លោកបានទៅសង្កេតមើលសព្វកន្លែងនៅទីអង្គរក៏បានឃើញរូបព្រះពោធិសត្វឈ្មោះ អវលោកកិតេស្វរ ជាច្រើននិងប្រាសាទទាំង៤ ដែលមាននៅត្រង់ជ្រុងកំផែងខាងក្រៅទាំង៤ នឹងហៅជាងប្រាសាទក្លោងទ្វារអង្គរធំ តែហៅជាងនៅគ្រប់ទ្វារទាំងអស់ជ្រុះអស់ហើយ ឃើញសល់នៅតែហៅជាងខាងក្នុងទ្វារជ័យ១ ហៅជាងនោះក៏របេះធ្លាក់ខ្លះ ប៉ុន្តែនៅមានរូបចម្លាក់អាចឲ្យសង្កាត់ទៅយល់ច្បាប់ប្រាកដបានថា ជារូបអវលោកិតេស្វរ ទាំងហៅជាងប្រសាទបាយន័ ក៏លោកហ្វីណូត៍ បានសង្កេតទៅឃើញមានរូបអវលោកិតេស្វរ ដែលជាអ្នកគ្រប់គ្រងរក្សាអ្នកទាំងអស់កាន់ព្រះពុទ្ធសាសនាលោក ហ្វីណូត៍បានសង្កេតទៅឃើញដូចនេះ ក៏ចូលចិត្តថាអង្គរធំនេះជាទី គឺអ្នកកាន់ព្រះពុទ្ធសាសនាខាងមហាយានបានកសាងឡើងជាងមុន។*

*ហេតុដូចនេះគួរតែចូលចិត្តថាមកនៅលើទូកទាំងអស់ប្រហែលជាមុខអាវលោកគេផ្ទះស្មោរព្រោះគេធ្វើឲ្យបានទៅគ្រប់ទិសទាំង 4 ដូចនេះដោយសម្តែងឲ្យឃើញថាព្រះនាគមើលទៅក្នុងទិសទាំង 4 ដើម្បីៗជួយអភិបាលរក្សាអស់ទាំងអ្នកកាន់ព្រះពុទ្ធសាសនាដែលស្ថិតនៅក្នុងទិសទាំងបួន។*

*គ្រប់ទ្វារទាំងអស់ត្រង់កន្លែងវង្វង់ទ្វារទាំងសង្ខាងមានចិត្តដើម្បី 490 ឡានទៅកាន់បន្ទប់ទាំងសង្ខាង។*

*គ្រប់ទ្វារទាំងអស់ត្រង់កន្លែងវង្វង់ទ្វារទាំងសង្ខាងមានចិត្តដើម្បី 490 ឡានទៅកាន់បន្ទប់ទាំងសង្ខាងយកសោ 5 ទ្រង់សោយរាជ្យទីក្រុងនោះមិនបានស្ថិតនៅមាំមួនជានិច្ចទេជុំការគេលះបង់ចោលទីនោះហើយទៅតាក់តែងកន្លែងដទៃទៀតជាទីប្រជុំជនការត្រឡប់មកយកពីអង្គរធំនេះវិញជាទីក្រុងវែងលុះយូរមកដល់សុទ្ធមកស្តេចជាន់ក្រោយក៏បោះបង់ចោលទីក្រុងអង្គរធំនេះមែនទែនដោយហេតុការណ៍សង្គ្រាមមានសត្រូវលុកលុយចូលមក។*

*តាមសៀវភៅរបស់ចិនជាមួយចោលតាកួនគេនិយាយថាអង្គរធំជាទីក្រុងធំណាបរិបូណ៌ដែលសម្បត្តិហ្នឹងកុសករដល់ប្រាសាទល្អជាច្រើនកាលចូលទៅតាមទ្វារខាងត្បូងហើយទៅតាមផលតទៅចំនួន 1500 ម៉ែត្រទៅដល់ពីរវាថាបាយ័ន។*



*ច្រកទ្វារខាងត្បូង*



*ទិដ្ឋភាពពីចម្ងាយ*



*ផ្លូវច្រកចូល*



# ប្រាសាទបាយ័ន

# ប្រាសាទបាយ័ន

ទីបាយ័ននេះស្ថិតនៅចំពាក់កណ្តាលក្រុងបាយ័ននេះប្រហែលជាទីចាស់ជាងប្រាសាទដទៃ ក្នុងអង្គធំ កាលបើក្រឡេកមើលទ្រង់ទ្រាយ តាំងពីខាងក្រោមដរាបដល់ទៅថ្នាក់កំពូលឃើញមានទ្រង់មានសណ្ឋានដូចជាភ្នំ ព្រោះហេតុនេះបានជាពីដើមគេឲ្យឈ្មោះបាយ័នថាយសោធរគិរី គឺភ្នំទ្រទ្រង់នូវយស។



ទិដ្ឋភាពពីចម្ងាយ

ទីបាយ័ននេះ អស់ពួកមេការបារាំងនឹងពួកអ្នកប្រាជ្ញបារាំងបានមកពិនិត្យសង្កេតមើលបែបផែន និងទំនងការកសាងឃើញថាបាយ័ននេះ មិនមែនគេកសាងតែម្តងទេ គឺគេធ្វើច្រើនលើកច្រើនដង បានជាគេឃើញមានថ្មស្ថិតនៅជាសង្កាត់ៗ ជាជាន់ៗ រដឹបរដុបច្រើន ត្រង់ជាន់ទី៣ លុះដល់គេរើអស់ទាំងថ្មដែលតម្រួតលើគ្នានោះចេញខ្លះទៅ ក៏ឃើញរូបចម្លាក់ អវលោកិតេស្វរ នៅទីខាងក្នុងនោះកាលបើឃើញដូចនេះហើយគេក៏នឹកស្មានថាទីបាយ័ននេះ កាលពីដើមប្រហែលជាពួកអ្នកកាន់ព្រះពុទ្ធសាសនាលើខាងមហាយានបានគេកសាងលុះដល់មកជាន់ក្រោយទំនងជាពួកអ្នកកាន់សាសនាព្រាហ្មណ៍ មកនៅថែរក្សាទីបាយ័ន នេះក៏យកដុំថ្មទៅដាក់ខ្ទប់បិទ រូបអាវលោកិតេស្វរនោះ មិនឲ្យគេមើលទៅឃើញ មិនតែប៉ុណ្ណោះឡើយគេបានសង្កេតមើលនៅសសរឃើញរូបចម្លាក់ ចំណែកខាងព្រះពុទ្ធសាសនា តែមិនច្បាំងដោយមានស្នាមកោសលុបរូបនោះចេញ ហើយឆ្លាក់រូបចំណែកខាងសាសនា ព្រាហ្មណ៍ឡើងវិញត្រង់កន្លែងនោះ។



រូបចម្លាក់លើជញ្ជាំង



នៅខាងក្រៅប្រាសាទ



រូបចម្លាក់លើជញ្ជាំង

បាយ័ននេះប្រកបដោយជាន់៣មានទ្វារសំរាប់ចូលទៅបានគ្រប់ទិសទាំង៤តែទ្វារធំនៅខាងកើត ហេតុនោះគួរតែនឹងចូលទៅតាមទ្វារខាងកើត បើចូលទៅតាមទ្វារខាងកើត មុនដែល នឹងចូលទៅនឹងឃើញទីផ្ទៃថ្ម ១ខ្ពស់ពីផែនដី ស្មើគ្នានឹងផ្ទៃជាន់ទី១ ក្នុងបាយ័ន ទីផ្ទៃថ្មមនោះវែងត្រង់មកខាងកើត មានជណ្ដើរចំនួន ៧ទៅ៨កាំសម្រាប់ចុះឡើងពីខាងកើតកាលបើឡើងតាម ជណ្ដើរនោះដល់ទៅខាងលើទីផ្ទៃថ្ម នឹងឃើញរូបសត្វសីហ ត្រង់ក្បាលជណ្ដើរខ្វះនិងរូបនាគជាប្រកាន់ដៃនៅត្រង់ក្បាលនាគនោះ ឃើញមានរូបគ្រុឌជិះលើក្បាលនាគ រូបសត្វដែលជាគ្រឿងប្រដាប់នៅទីនោះឃើញមានភាពទំនងជាអ្នករបស់ខ្មែរហើយឃើញមានកន្ទែងស្រះ២ នៅសងខាងពីផ្ទៃនោះ លុះដើរតាមទីផ្ទៃថ្មនោះទៅក៏ដល់ទៅជាន់ទី១។

ជាន់ទី១នេះត្រង់កន្ទែងដែលចូលទៅឃើញមានកន្ទែងទ្វារ ២ទៅសង្កាត់នៅទ្វារនោះកាលពីដើមប្រហែលជាគេធ្វើមានដំបូលជាយ៉ជាប់គ្នាពីរពោងថែវជាន់ទី ១ មកតែឥឡូវនេះបែកបាក់ខ្ទេចអស់ហើយឃើញនៅតែសសរៗ ទាំងនោះមានក្បាច់ ចម្លាក់ជារូបល្ខោនល្អណាស់ទៅពីកន្ទែងទ្វារបន្តិចទៅ ក៏ដល់ទៅកន្ទែងពោងថែវៗ នោះកាលពីដើមមានដំបូលជុំវិញតែឥឡូវនេះបាក់បែកអស់ហើយឃើញនៅតែសសរនិងជញ្ជាំង ឯសពោងថែវជុំវិញនោះឃើញមានក្បាច់ចម្លាក់ជារូបល្ខោនដូចសសរទ្វារខាងក្រៅ ឯអញ្ចឹងជុំវិញនោះឃើញមានក្បាច់ចម្លាក់រម្ទេចនិយាយអំពីរឿងរ៉ាវផ្សេងៗហើយនិងរឿងពង្សាវតាជាក្បាច់រម្ទេចល្អណាស់ ក្នុងរឿងទាំងអស់នោះ សង្កេតមើលទៅឃើញគ្រឿងប្រដាប់ធ្វើការ គ្រឿងក្មេងនិងគ្រឿងប្រដាប់អ្នកនេសាទក៏ឃើញដូចគ្នានិងគ្រឿងប្រដាប់ដែលគេប្រើប្រាស់សព្វថ្ងៃនេះដែរ ហើយឃើញអស់ទាំងមនុស្សជាតិផ្សេងៗមានសំលៀកបំពាក់បំពាក់តាមទម្លាប់របស់ជាតិនោះផងៗល។

ជាន់ទី ២ នេះមានពោងថែវព័ទ្ធជុំវិញនៅពោងថែវនោះ គេធ្វើជាប្រាសាទមានកំពូលខ្ពស់ឡើងចំនួន ១៦ ប្រាសានៅត្រង់ជ្រុងទាំង៤ នៃពោងថែវ ខាងក្នុងមានពោងថែវជារំពត់ញោចតាមជ្រុង នៅពោងតែជ្រុងមួយៗ ប្រាសាទខ្ពស់ឡើងបីកំពូលប្រាសាទទាំងអស់នោះ សុទ្ធតែប្រដាប់ដោយមុខ៤ នៅជញ្ជាំងពោងថែវជុំវិញមានក្បាច់រម្ទេចនិយាយពីរឿងអស្ចារ្យខាងចំណែកសាសនាព្រាហ្មណ៍។



រូបចម្លាក់លើជញ្ជាំង

ជាន់ទី ៣ នេះមានទីផ្ទៃថ្មខ្ពស់ឡើងជាន់ទី ២ត្រង់កណ្ដាលទីផ្ទៃនោះមានប្រាសាទ១ខ្ពស់នឹងធំជាងប្រាសាទទាំង ២០ ដែលមាននៅជុំវិញ ឯកំពូលប្រាសាទកណ្ដាល ព្រមទាំងប្រាសាទទាំង 20 នោះ សុទ្ធតែប្រដាប់ទៅមុខ៤ទាំងអស់ ខាងក្នុងប្រាសាទកណ្ដាល កាលពីដើមមានទីកន្លែងសម្រាប់ដំកល់លិង្គព្រះឥសូរ នៅក្នុងបន្ទប់ខ្ទះដែលមាននៅប្រាសាទកណ្ដាលនោះ ឃើញមានព្រះពុទ្ធរូបខាងលទ្ធិហិនយាន តែព្រះពុទ្ធរូបទាំងនោះ គេទើបនឹងយកទៅដាក់ក្នុងកាលជាខាងក្រោយទេ។

បណ្ដាលក្បាច់ចម្លាក់ ដែលមាននៅទីអង្គរធំឃើញមានក្បាច់ចម្លាក់នៅប្រាសាទនោះត្រង់ទីអមសងខាងទ្វារបង្អួចនិងខាងលើ ខាងក្រោមទ្វារ បង្អួច ជាក្បាច់ចម្លាក់ល្អសំខាន់ដោយបែប១យ៉ាងដែរ។

ពីបាយ័ននោះបើឡើងទៅដល់ជាន់ទី៣ក្នុងវេលាដែលព្រះអាទិត្យ រៀបនឹងអស្តង្គតនោះ ល្អមើលណាស់ ព្រោះប្រាសាទទាំងអស់ឃើញហាក់ដូចជាផុសលេចចេញពីក្នុងព្រៃកាលណារស្មីព្រះអាទិត្យចាំមកក៏ឃើញអស់ទាំងមុខ៤ដែលនឹងកំពូលប្រាសាទទាំងអស់ដូចជាញញឹមគ្រប់មុខទាំងអស់។

កាលបើចុះពីបាយ័នមក ត្រូវដើរទៅតាមផ្លូវថ្នល់ខាងត្បូងវង់ទីបាយ័ននោះ និងឃើញចេតិយមានសណ្ឋានជាប្រាសាទតូច១នៅច្រកផ្លូវដែលគេទើបនឹងធ្វើ ដើម្បីទុកអោយគ្រឿងរំលឹកដល់លោកកុម្មែ ដែលជាអ្នកគ្រប់គ្រងថែរក្សានៅទីអង្គរនោះមុនគេលុះដល់មកខាងទិសពាយព្យ នឹងឃើញវាហារថ្មី១ គេទើបនឹងសាងនៅជិតផ្លូវថ្នល់ ក្នុងវិហារនោះ មានព្រះពុទ្ធរូបចូលនិព្វាន ១ព្រះអង្គល្អណាស់ ជាព្រះពុទ្ធរូបខាងលទ្ធិហិនយាន គេសាងប្រហែលជាក្នុងរវាង ៤ ទៅ ៥ រយឆ្នាំមុននេះ តែព្រះពុទ្ធរូបនោះសព្វថ្ងៃនេះគេលើកដាក់តម្កល់លើបល្ល័ង្កជាមួយគ្នានិងព្រះពុទ្ធរូបថ្មីដែលគេទើបនឹងសាង។

នៅខាងទិសពាយព្យនៃបាយ័ន មានប្រាសាទជាច្រើនមានប្រាសាទបាពួនជាដើម ទីត្រង់នោះហើយដែលជាទីបរមរាជវាំងពីដើម។



រូបចម្លាក់លើជញ្ជាំង



# ប្រាសាទបាពួន

# ប្រាសាទបាពួន

ដែលនឹងទៅកាន់ប្រាសាទបាពួននោះ បើទៅតាមផ្លូវថ្នល់ត្រង់ទៅខាងជើង ដល់ទៅទីខាងមុខបាពួនត្រូវឡើងតាមជណ្តើរហើយដើរត្រង់ទៅខាងលិចទៅក៏បាន ឬទៅកាត់ព្រៃចូលទៅតាមផ្លូវជើងច្រកវិហារថ្មី ដែលនៅខាងទិសពាយព្យនៃបាយ័នក៏បាន បើទៅតាមផ្លូវកាត់ព្រៃចូលទៅចំនួន ៣០០ ម៉ែត្រក៏ដល់ទៅប្រាសាទបាពួន។



នៅខាងក្រៅប្រាសាទ

ប្រាសាទបាពួននេះគឺស្តេចឈ្មោះ ជ័យវរ្ម័នទី ៥ បានសង់នៅលើទីទួលតូច១ ដើម្បី ឧទ្ទិស្ស ថ្វាយដល់ទេវតាខាងសាសនាព្រាហ្មណ៍ឈ្មោះហេមស្រីង្គេស ប្រាសាទនោះកាលពីដើម ឈ្មោះថាហិមាទ្រ(ភ្នំមាស) នៅខាងលិចជិតជើងប្រាសាទនោះ កាលពីដើមឃើញមានថ្មគេរៀបខ្ពស់ឡើងមានសណ្ឋាន ជាព្រះពុទ្ធរូបចូលនិព្វាន បាំងទីប្រាសាទខាងលិច ថ្មដែលរៀបដូចនេះប្រហែលជាពួកអ្នកកាន់ព្រះពុទ្ធសាសនាខាងហីនយាន បានរៀបធ្វើឡើងក្នុងកាលជាខាងក្រោយ តែឥឡូវនេះគេកំពុងតែរើថ្មនោះចេញ។

ប្រាសាទនៅមានជាន់ ៣ និងប្រកបដោយរោងថែវមានជណ្តើរសម្រាប់ឡើងទៅគ្រប់ទិសទាំង ៤ តែសព្វថ្ងៃនេះឡើងបានទៅស្រួលតែតាមជណ្តើរខាងត្បូង។

សៀវភៅចំណាឈ្មោះចាវតាគួរនិយាយថា ប្រាសាទនោះជាប្រាសាទធំខ្ពស់ល្អសំខាន់១ក្នុងពួកប្រាសាទដែលមាននៅទីអង្គរធំ ហើយថាត្រង់កណ្តាលជាន់ទី ៣ មានប្រាសាទ១ តែសព្វថ្ងៃនេះត្រឡប់ទៅបាក់បែកច្រើនជាងប្រាសាទឯទៀត។

នៅទីជញ្ជាំងសងខាងទ្វារទាំងអស់ក្នុងជាន់ទី ២ ឃើញមានក្បាច់រម្ទេចជាសង្កាត់។ ល្អណាស់ សុទ្ធតែនិយាយពីរឿងអស្ចារ្យ ខាងចំណែកសាសនាព្រាហ្មណ៍ និងរឿងរាមាយណ ។

កាលបើចេញមកវិញ ត្រូវដើរមកតាមផ្លូវថ្មត្រង់មកខាងកើត ឯផ្លូវនោះកាលពីដើមជាថ្មល្អមានសណ្ឋានដូចជាស្ពានព្រោះមានសសរថ្មទល់ទ្រពីក្រោម ឥឡូវនេះបាក់បែកអស់ហើយសល់នៅតែសសរ ប៉ុន្តែគេបានរៀបចំលើកដុំថ្មដាក់លើក្បាលសសរគ្នា ល្មមដើរបាន លុះដើរតាមផ្លូវនោះមកដរាបដល់មកមាត់ជណ្តើរ ក៏ចុះដើរទៅខាងជើង នឹងឃើញទីព្រះលានស្តេច ។



# ទីព្រះលានស្តេច

# ទីព្រះលានស្ដេច

ទីព្រះលាននេះស្ថិតនៅខាងជើងត្រង់ពីបាយ័នមក មានផ្ទៃខ្ពស់ឡើងពីផែនដី ទទឹងចំនួន១៤ម៉ែត្រ បណ្ដោយចំនួន ៣០០ ម៉ែត្រ រៀបត្រង់ដូចជាកំផែងពីខាងត្បូង ទៅខាងជើងមានរូបនាគ ជាប្រកាន់ដៃទាំងសងខាង ទីព្រលាននោះប្រហែលជាទីសម្រាប់ស្ដេចយាងចេញមកក្រសាល ដើម្បីនឹងទតអស់ទាំងមនុស្សទាំងដើរតាមផ្លូវ។



រូបចម្លាក់លើជញ្ជាំង

ទីព្រះលាននេះមានទីយ៉លយចេញមកខាងកើត ៥កន្លែង គឺទីយ៉ ៣ នៅត្រង់កណ្ដាល ទីយ៉ពីរទៀត នៅទីបំផុតទាំងសងខាង នៅត្រង់កើយ ទ៉យបំផុតទាំងសងខាងមានចម្លាក់រម្ទេច ជារូបដំរី ត្រង់កើយទីយ៉កណ្ដាល មានចម្លាក់រម្ទេចជាគ្រុឌជាទ្រទ្រី នោះត្រង់កើយទីយ៉តូចទាំងសងខាងមានចម្លាក់រម្ទេច ជារូបដំរីដែរ រូបដំរីខេត្តប៉ែកខាងជើងនៃចម្លាក់ដើម្បីជារូបគ្រុឌ។

កាលបើត្រូវការនឹងទៅមើលប្រាសាទវិមានអាកាស ត្រូវឡើងតាមជណ្ដើរត្រង់ទីម៉កណ្ដាល ឡើងដល់ទីខាងលើទីព្រះលាននឹងឃើញរូបសត្វសីហនៅជាសងខាង ហើយឃើញមានរូបនាគជាប្រកាន់ដៃផង លុះដើរត្រង់ទិសខាងលិចនឹកដល់ទៅទ្វារកំផែង តរពីទ្វាកំផែង នោះទៅប្រហែលជា ១៥០ ម៉ែត្រក៏ដល់វិមានអាកាស។



នៅខាងក្រៅប្រាសាទ



នៅខាងក្រៅប្រាសាទ



# វិមានអាកាស

# វិមានអាកាស

វិមាននេះស្ថិតនៅត្រង់កណ្ដាលព្រះបរមរាជវាំង គេចាប់ធ្វើឡើង ក្នុងរាជស្ដេចទ្រង់ព្រះនាម យសោវរម័ន ដល់មកក្នុងរាជស្ដេចទ្រង់ព្រះនាមហស៌វរម័នទើបហាលយស្រេច វិមាននោះមានសណ្ឋានជាតួប្រាង្គណ៌ប្រកបដោយជាន់ ៣ ត្រង់ជាន់ខាងលើមានរោងថែវតូចព័ទ្ធជុំវិញ មាន ជណ្ដើរ ៤ សម្រាប់ឡើងទៅលើទីប្រាង្គនោះគ្រប់ទិសទាំង៤ តែជណ្ដើរដែលឡើងទៅស្រួលនោះ គឺជណ្ដើរទិសខាងលិច ត្រង់ផ្ទៃកណ្ដាលជាន់ទី៣ មានប្រាសាទ ១ តែឥឡូវនេះបាក់បែកជាច្រើនណាស់ហើយវិមាននេះគេសាងដើម្បីថ្វាយដល់ទេវតា ដែលជាអ្នករក្សាទីបរម៌រាជវាំងព្រមទាំងព្រះញាតិវង្សានុវង្ស។

តាមសៀវភៅចិនឈ្មោះ ចាវតាក្វន គេនិយាយថា មានរឿងព្រេងថា ស្ដេចតែងយាងមកជួបក្រសាលសប្បាយ ដោយនាងនាគីនៅប្រាសាទនោះរាល់ល្ងាចៗ វិមាននេះល្អមើលណាស់ ព្រោះគេធ្វើដោយថ្មបាយក្រៀមលាយដោយថ្មពណ៌ប្រផេះខ្ចះ។



នៅខាងក្រៅប្រាសាទ

កាលចេញពីវិមានអាកាស គួរទៅមើលកន្លែងស្រះចាស់ពីបុរាណ ១ ស្រះនោះស្ថិតនៅត្រង់ពីខាងជើងវិមានអាកាសដែលនឹងទៅមើលស្រះនោះ ត្រូវដើរតាមផ្លូវជើង កាត់ព្រៃទៅខាងជើងចំនួន១០០ម៉ែត្រ ក៏ដល់ទៅកន្លែងស្រះ នៅមាត់ស្រះនោះមានថ្មជាថ្នាក់ៗសម្រាប់ចុះទៅក្នុងស្រះនៅក្នុងថ្នាក់នីមួយៗសុទ្ធតែមានក្បាច់រម្ទេចជារូបផ្សេងៗ ថ្នាក់ខាងក្រោមឃើញមានរូបសត្វទឹកមានត្រីនឹងមករកជាដើម ថ្នាក់កណ្ដាលឃើញមានរូបនាគានឹងនាគីនឹងរូបមនុស្សខ្លះ ថ្នាក់ខាងលើឃើញមានរូបទេវតាយក្ស នឹងគ្រុឌ ថ្នាក់ទាំង៣ នេះប្រហែលជាគេធ្វើដោយទុកជាប្រស្នា ថ្នាក់ក្រោមទុកជាទឹក ថ្នាក់កណ្ដាលទុកជាផែនដី ថ្នាក់លើទុកជាអាកាស។

កាលបើមើលទីស្រះនោះរួចហើយ ត្រូវដើរត្រឡប់មកកាន់ផ្លូវខាងមុខវិមានអាកាសវិញ ហើយដើរមកខាងកើត តាមផ្លូវដដែល ជរាបមកដល់ទីព្រះលានស្ដេច លុះចុះទីព្រះលាននោះមក ផាកដើរទៅខាងជើងបន្តិច ក៏នឹងឃើញទីលាន ១ឈ្មោះថាទីលានស្ដេចគម្លង់។



# ទីលានស្តេចគម្លង់

# ទីលានស្តេចគម្លង់

ទីលាននេះស្ថិតនៅជាខាងជើងទីព្រះលានស្តេច ចម្ងាយប្រហែល ២ទៅ៣ម៉ែត្រពីគ្នា មានកម្ពស់ជាង៦ម៉ែត្រដែលនឹងឡើងទៅលើទីលាននោះ ត្រូវចូលទៅតាមផ្លូវតូច ១ បត់ចុះឡើងក្នុងទីលាននោះលុះដល់ទៅខាងលើ ក៏នឹងបានឃើញរូប ១ដែលគេហៅថា រូបស្តេចគម្លង់ នៅជញ្ជាំងខាងក្រៅនឹងខាងក្នុងទីលាននោះ ឃើញមានរូបចម្លាក់រម្មេចជារូបនាគ នឹងរូបទេវតាជាច្រើនៗល។






រូបចម្លាក់ផ្សេងៗ

កាលបើចុះពីលានស្តេចគម្លង់មក ត្រូវទៅតាមផ្លូវជើងកាត់ព្រៃត្រង់ទៅទិសពាយព្យ ចម្ងាយប្រមាណជាង១០០ម៉ែត្រក៏ដល់ទៅទី១ហៅថាទេពប្រណម្យ ឬនឹងទៅតាមផ្លូវថ្នល់ខាងមមុខក៏បានទៅពីទីលាននោះទៅចំនួន ១០០ម៉ែត្រមានផ្លូវជើង ១បែរទៅខាងលិច ដើរតាមផ្លូវនោះទៅក៏ដល់ទៅទីទេពប្រណម្យដូចគ្នា។



# ទេពប្រណម្យ

# ទេពប្រណម្យ



នៅខាងក្រៅ

ទេពប្រណម្យនេះ ជាទីលានដីដែលគេរៀបចំបម្រុងនឹងធ្វើវិហារខាងព្រះពុទ្ធសាសនានៅលើទីលានបំផុតខាងលិច ឃើញមានព្រះពុទ្ធរូបថ្ម ១ព្រះអង្គ ពែនលើបល្ល័ង្កបែព្រះភក្ត្រទៅខាងកើត មានកម្ពស់៤ម៉ែត្រ ឯព្រះពុទ្ធរូបនោះមើលទៅឃើញសម្បើមណាស់ ព្រោះនៅក្នុងព្រៃស្ងាត់តែ ១ ព្រះអង្គ ហើយសក្តិសមល្អ តាំងពីព្រះភក្ត្រដរាបដល់ព្រះភ្នែន នៅលើទីលានខាងមុខព្រះពុទ្ធរូបនោះ ឆៀងខាងត្បូងបន្តិចមានសសរថ្ម៤ជ្រុង ១ប្រកបដោយសិលាចារិក និយាយសរសើរពីបុណ្យស្ដេចទ្រង់ព្រះនាមសោវរម័ន នឹងនិយាយពីការកសាងទីកន្លែង ខាងព្រះពុទ្ធសាសនា សសរថ្មព្រមទាំងសិលាចារិកនោះ សព្វថ្ងៃនេះនៅល្អទាំងអស់ នៅខាងក្រោយព្រះពុទ្ធរូបនោះ ផុតពីទីលាននោះទៅ ឃើញមានព្រះពុទ្ធរូបទ្រង់ឈរ ១ព្រះអង្គ សម្តែងអាការព្រះហស្តជាអភយមុទ្រ គឺពព្រះហសត្ត តែព្រះពុទ្ធរូបនោះសព្វថ្ងៃនេះរបេះរបកត្រង់ព្រះភក្តអស់ នៅសល់តែខាងព្រះសរិៗ



នៅខាងក្រៅ



នៅខាងក្រៅ



# ព្រះបាលិលេ្យ

# ព្រះបាលិឡ្យៃ



*នៅពីក្រោយប្រាសាទ*



*នៅពីក្រោយប្រាសាទ*

ប្រាសាទបាលិឡ្យៃនេះស្ថិតនៅជាខាងលិច គៀងខាងជើងទេពប្រណម្យ មានមុខបែទៅខាងកើត នៅទីប្រាសាទនោះមានក្បាច់ចម្លាក់ល្អណាស់ឃើញមានរូបចម្លាក់ខាងព្រះពុទ្ធសាសនាមហាយានដោយច្រើន ហើយឃើញមានរូបចម្លាក់ខាងសាសនាព្រាហ្មណ៍ខ្លះដែរ ដូចជានៅប្រាសាទកណ្តាល ត្រង់មេទ្វារខាងលើទិសខាងកើត ឃើញរូបព្រះឥន្ទ្រជិះលើដំរីអៃរាវណ មានក្បាល ៣ត្រង់មេទ្វារខាងលើទិសខាងលិច ឃើញមានរូបព្រះព្រហ្មជិះលើហង្ស នៅសុំទ្វារប្រាសាទខាងកើត ឃើញមាព្រះពុទ្ធរូបនឹងថ្មដែលបាក់ធ្លាក់ចុះមកខាងក្រោម ក៏ឃើញមានព្រះពុទ្ធរូបជាច្រើន នៅខាងមុខប្រាសាទនោះមានទីលានថ្ម ១មានជណ្តើរសម្រាប់ចុះឡើងគ្រប់ទិសទាំង ៤ នៅសងខាងទីលាននោះមានរូបនាគជាប្រកាន់ដៃ។



*នៅពីក្រោយប្រាសាទ*



# ព្រះពិធូរ

# ព្រះពិធូរ

នៅខាងកើតទេពប្រណម្យ មានពួកប្រាសាទជាច្រើនហៅថាព្រះពិធូរ ក្នុងពួកប្រាសាទទាំងនេះ ប្រាសាទជាច្រើនហៅថាព្រះពិធូរ ក្នុងពួកប្រាសាទទាំងនោះ ប្រាសាទខ្លះគេធ្វើដើម្បីឧទ្ទិស្សដល់ព្រះពុទ្ធសាសនា ខ្លះដើម្បីឧទ្ទិស្សដល់សាសនាព្រាហ្មណ៍ ក្នុងព្រះពិធូរនោះ មិនមានតែប្រាសាទនោះឡើយ មានទាំងទីលាននឹងស្រះផង រួមទីនោះទាំងអស់ហៅថាព្រះពិធូរឯក្បាច់ចម្លាក់ដែលមានក្នុងប្រាសាទទាំងនោះ ជាក្បាច់ល្អគ្រាន់បើដែរ។





រូបភាពពីខាងក្រោម

រូបខាងជើង

កាលបើដើរត្រង់ទៅខាងកើតដល់ទៅមាត់ស្រះនឹងឃើញរូបដំរីថ្ម១គូល្អណាស់មានទ្រង់ហាក់ដំរីរស់មែនទែន។



រូបខាងក្នុងប្រាសាទ



# ឃ្លាំង

# ឃ្លាំង


រូបភាពពីខាងក្រោម


នៅពីក្រោយប្រាសាទ


នៅពីក្រោយប្រាសាទ

កាលបើដើរចេញពីព្រះពិធូរ ទៅតាមផ្លូវខាងត្បូង នឹងបានឃើញប្រាសាទ ២ ដែលគេហៅថាឃ្លាំង នៅអមសងខាងផ្លូវដែលជាផ្លូវត្រង់ទៅលើទ្វារជ័យ ឯឃ្លាំងទាំង២នោះឃ្លាំមួយៗមានប្រាសាទតូចៗប្រាំ ស្ថិតនៅពីខាងលិចជាជួរ ពីខាងជើងទៅខាងត្បូង ឯប្រាសាទតូចៗនោះ បើតាមរឿងព្រេងនិយាយថា ប្រាសាទទាំងនោះជាទីសម្រាប់ចងព្រាត់ ហើយដើរស្ទួរលើព្រាត់នោះ។ សព្វថ្ងៃនេះគេកំពុងតែរៀបចំ ឃ្លាំងនោះធ្វើឲ្យស្អាតល្អឡើងវិញ។

កាលបើមើលប្រាសាទក្នុងទីអង្គរធំរួចហើយ ត្រូវទៅតាមផ្លូវជាចន្លោះឃ្លាំងទាំង ២នោះត្រង់ ទៅខាងកើតទៅតាមផ្លូវនោះទៅមិនឆ្ងាយក៏នឹងដល់ទៅទ្វារជ័យ លុះចេញពីទ្វារជ័យនោះទៅ ត្រូវ ទៅតាមផ្លូវដូចបាននិយាយ ពីខាងដើមរួចហើយទៅតរពីផ្លូវនោះត្រង់ទៅខាងកើតបន្តិចទៅ ក៏នឹង ឃើញប្រាសាទ២ប្រាសាទ ១នៅខាងជើងផ្លូវឈ្មោះថាចុម្ពាណុនប្រាសាទ១ទៀតនៅខាងត្បូងផ្លូវ ឈ្មោះថាចៅសាយ ប្រាសាទទាំង២នោះ គេធ្វើដើម្បីឧទ្ទិស្សដល់សាសនាព្រហ្មណ៍ ទៅតរពីនោះ បន្តិចទៅទៀតនឹងដល់ទៅស្ទឹងសៀមរាប ហើយនឹងឃើញកន្លែងស្ពានថ្មចាស់បាក់បែកពីបុរាណ ១នៅ ស្របស្ពានឈើ ដែលគេទើបនឹងធ្វើថ្មី ទៅតរពីស្ទឹងនោះបន្តិចទៅ ហើយបែរខាងត្បូងតាមផ្លូវថ្នល់ នឹង ឃើញប្រាសាទ១ឈ្មោះថាប្រាសាទតាកែវ។



# ប្រាសាទតាកែវ

# ប្រាសាទតាកែវ

ប្រាសាទតាកែវនេះជាប្រាសាទល្អ១ក្នុងទីអង្គរ គេសាងក្នុងរវាងពុទ្ធសករាជជាង១៥០០ដើម្បីឧទ្ទិស្សថ្វាយដល់សាសនាព្រាហ្មណ៍។



*រូបភាពប្រាសាទតាកែវ*



*អង្គរ តាកែវ*

ដែលនឹងចូលទៅកាន់ប្រាសាទនោះ ត្រូវទៅតាមផ្លូវខាងកើត ទីទ្រប្រាសាទនោះមាន៣ជាន់ នៅជាន់ទី២ មានរោងថែវព័ទ្ធជុំវិញ ហើយមានបណ្ណាល័យ២នៅសងខាងទ្វារខាងកើតជាន់ទី៣មានសណ្ឋានជាតួប្រាង្គណ៌ ៣ថ្នាក់នៅលើប្រាង្គណ៌នោះ មានប្រាសាទ៥ប្រាសាទកណ្តាលធំ នឹងខ្ពស់ជាងប្រាសាទទាំង ៤ ដែលមាននៅក្នុងទិសទាំង៤ ហើយមានជណ្តើរសម្រាប់ឡើងទៅគ្រប់ទិតទាំង៤ ក្បាច់ចម្លាក់ដែលមាននៅនឹងប្រាង្គណ៌ប្រាសាទនោះ ឃើញមានតែត្រង់កន្ទែងមេទ្វារនឹងស៊ុមទ្វារ មិនមានដេរដាសពាសពេញទាំងអស់ទេ ឯប្រាសាទនោះទោះបីនឹងមានក្បាច់ចម្លាក់ច្រើនមែន តែក៏គង់នៅល្អមើល ព្រោះទ្រង់ទ្រាយប្រាសាទនោះសមល្អណាស់ កាលបើក្រឡេកមើលទៅនឹងឃើញមានពណ៌ផ្ទាស់រម្ទេចល្អ ព្រោះប្រាសាទនោះគេធ្វើដោយថ្មបាយក្រៀមលាយប្រឡំគ្នាដោយថ្មពណ៌ប្រផេះ។

កាលបើឃើញចេញពីប្រាសាទតាកែវតាមផ្លូវខាងកើត ហើយបែរតាមថ្នល់បែរទៅខាងត្បូងទៅនឹងដល់ទៅប្រាសាទ១ទៀតឈ្មោះថាប្រាសាទតាព្រហ្ម។



*ប្រាសាទតាកែវព្រះរាជាណាចក្រកម្ពុជា*



# ប្រាសាទតាព្រហ្ម

# ប្រាសាទតាព្រហ្ម

ប្រាសាទតាព្រហ្មនេះ គេសាងក្នុងរវាងពុទ្ធសករាជជាង ១៤៥០នឹង ១៥០០នៅប្រាសាទនេះ គេឃើញមានរូបចម្លាក់ដែល មានក្នុងសាសនាទាំង ២ គឺពុទ្ធសាសនាខាងមហាយាន នឹងសាសនា



ចម្លាក់នៅប្រាសាទតាព្រហ្ម



ដើមឈើនៅលើប្រាសាទ

ព្រាហ្មណ៍។

ប្រាសាទនោះសព្វថ្ងៃនេះ ស្ថិតនៅក្នុងកណ្តាលព្រៃ គេមិនទាន់កាប់ឆ្កាព្រៃធ្វើឲ្យស្អាត ដូចជាប្រាសាទឯទៀតៗទៀតនៅឡើយទេ ។

ប្រាសាទនេះប្រកបដោយកំផែង ៥ជាន់កំផែងខាងក្រៅបំផុត បណ្តោយពីខាងកើតទៅខាងលិចចំនួន ១០០០ ម៉ែត្រទទឹងពីខាងជើងទៅខាងត្បូង ប្រហែលជាង ៦០០ ម៉ែត្រ នៅកំផែងខាងក្រៅនេះ មានទ្វារ៤ គ្រប់ទិសទាំង៤ នៅខាងលើទ្វារនីមួយៗ នោះគេធ្វើក្លោងជាប្រាសាទ មានកំពូលប្រដាប់ដោយមុខ៤ បែរទៅគ្រប់ទិសទាំង ៤ នៅត្រង់ជ្រុងទាំងបួននៃប្រាសាទទ្វារមួយៗមានរូប គ្រុឌមួយៗនៅគ្រប់ជ្រុងឯទ្វារដែលចេញចូលបានសព្វថ្ងៃនេះ គឺទ្វារខាងកើតនឹងខាងលិច តែទ្វារខាងកើត ជាទ្វារធំ បើកចូលទៅតាមទ្វារខាងកើត លុះចូលផុតពីកំពែងទី ១ ខាងក្រៅទៅ ត្រូវដើរចូលទៅតាមផ្លូវដើង ដើរបន្តិចទៅក៏ដល់ទៅផ្លូវថ្ម ជាផ្លូវឆ្លងកាត់ស្រះ ដែលមាននៅដោយជុំវិញកំផែងទី ២ ដើរតាមផ្លូវនោះទៅក៏ដល់ទៅ



ព្រះភ័ក្រតាព្រហ្ម

ទ្វារកំផែងទី ២ នៅត្រង់ទ្វារនោះគេធ្វើជាប្រាសាទមានកំពូល ហើយមានទ្វារតូចៗពីរនៅសងខាងទ្វារធំ ខាងលើធ្វើជាដំបូលមានសណ្ឋានដូចរោងថែវ នៅទីសងខាងទ្វារឃើញមានរូបចម្លាក់ ត្រង់រឿងព្រះផ្ចាញ់មារ ការចូលផុតពីទ្វារកំផែងទី ២ ទៅ នឹងឃើញប្រាសាទ១ បណ្តោយប្រហែលជា ៣០ ម៉ែត្រទទឹងប្រហែលជា ២០ ម៉ែត្រមានសណ្ឋានដូចជាសាលា តែបាក់បែកជាច្រើនណាស់ហើយ ឃើញសល់នៅតែ



នៅពីក្រោយប្រាសាទ

ជញ្ជាំងនិងសសរ នៅជញ្ជាំងខាងត្បូងនិងខាងជើង ត្រង់កន្លែងខាងលើនិងសងខាងទ្វារបង្អួច មានក្បាច់ចម្លាក់ល្អណាស់ទៅពីនោះទៅទៀតក៏ដល់ទៅកំផែងទី ៣ កំផែង នេះមានសណ្ឋានជារោងថែវព័ទ្ធជុំវិញ មានទ្វារបីៗគ្រប់ទិសទាំង៤ខាងលើទ្វារគេធ្វើជាប្រាសាទមានកំពូលខ្ពស់ឡើង ប្រកបដោយក្បាច់ចម្លាក់យ៉ាងល្អ លុះចូលផុតពីកំផែងទី៣ ទៅនឹងឃើញរោងថែវ៣ជួលដែលជាផ្លូវចូលទៅកាន់កំផែងទី ៤ ហើយមានរោងថែវ កាត់ពីខាងត្បូងទៅខាងជើង នៅក្នុងទីផ្ទៃចន្លោះកំផែងទី ៣ និងទី ៤ ជាសងខាងផ្លូវប៉ែកខាងកើត ឃើញមានប្រាសាទជាច្រើនសុទ្ធតែមានក្បាច់ចម្លាក់យ៉ាងល្អៗ នៅស៊ុមទ្វារប្រាសាទ១ ក្នុងទីផ្ទៃខាងត្បូង ឃើញរូបចម្លាក់ត្រង់រឿងព្រះប្រសូតិបាកព្រះឧទរនៃព្រះនាងសិរិមហាមាយានៃព្រះលុម្ពិនី ហើយឃើញរូបព្រះឥន្ទនិងរូបទេវតាជាច្រើន នៅសងខាងផ្លូវប៉ែកខាងលិចមានប្រាសាទពីរ ១ ខាងត្បូងធ្វើដោយថ្មពណ៌ប្រផេះ ១ ខាងជើងធ្វើដោយថ្មបាយក្រៀមប៉ែកទិសខាងត្បូងនឹងខាងជើង មានរោងថែវ២ ជួរ



រូបភាពចម្លាក់តាមមាត់ទ្វារ



រូបភាពចម្លាក់តាមមាត់ទ្វារ

តពីរោងថែវជាន់ទី ៣ ទៅភ្ជាប់នឹងរោងថែវជាន់ទី ៤។ កំផែងទី ៤ មានសណ្ឋានជារោងថែវជុំវិញ ហើយមានរោងថែវតភ្ជាប់ទៅកំផែងទី ៥ ដែលមានសណ្ឋានជារោងថែវជុំវិញ ត្រង់កណ្តាលមានប្រាសាទ ១ ធំនឹងខ្ពស់ជាងប្រាសាទទាំង ៨ ដែលមាននឹងរោងថែវជុំវិញនោះ ហើយមានរោងថែវជាប់ពីរោងថែវខាងកើតនឹងខាងលិច ត្រង់ទៅដល់ប្រាសាទកណ្តាលៗនោះមានល្វែងជា ៤ ជ្រុងហើយមានទ្វារច្រហ


នៅពីក្រោយប្រាសាទ


នៅពីក្រោយប្រាសាទ

គ្រប់ទិសទាំង៤ គេអាចចេញទៅបានតាមទ្វារខាងលិច ហើយដើរតាមរោងថែវត្រង់ទៅខាងលិចទៅ។ នៅក្នុងរោងថែវប្រាសាទតាព្រហ្មនេះ ឃើញមានសិលាចារឹកនិងសសរថ្ម ១ និយាយថាស្តេចទ្រង់ព្រះនាមជ័យវរ្ម័នទី ៧ បានត្រាសបង្គាប់ឲ្យសិលាចារិកនេះ ក្នុងពុទ្ធសករាជ ១៧២៨ព្រះអង្គសូមក្រាបថ្វាយបង្គំដល់ព្រះរត្នត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសំឃ នឹងអវលោកិតេស្វរ ហើយនិយាយពីព្រះអង្គបានធ្វើសឹកសង្គ្រាមមានជ័យជំនះ និងនិយាយពីប្រាសាទទាំងប៉ុន្មានដែលព្រះអង្គបានសាង។
ទីប្រាសាទតាព្រហ្មនេះ ប្រសិនបើអស់លោកអ្នកទាំងឡាយ បានទៅមើលក្នុងវេលាយប់ ក្នុងថ្ងៃដែលមានព្រះច័ន្ទពេញវង់ ដូចយ៉ាងក្នុងថ្ងៃ ១៥ កើត នឹងឃើញទីប្រាសាទនោះល្អមើលណាស់ ប៉ុន្តែត្រូវឱ្យរកពួកគ្គលី ដែលស្គាល់ផ្លូវជូនដំណើរទៅផង តែត្រូវឲ្យមានចន្ទុះឬចង្កៀងសម្រាប់បំភ្លឺផ្លូវ ក្នុងវេលាដែលដើរកាត់ព្រៃចូលទៅ។

បើការដែលចូលទៅតាមទ្វារខាងលិច នោះត្រូវចេញមកវិញតាមទ្វារខាងកើត លុះចេញផុតពីទ្វារកំផែងខាងក្រោមកហើយត្រូវដើរបែរទៅខាងត្បូងទៅ ក៏នឹងឃើញប្រាសាទបន្ទាយក្តី ព្រោះប្រាសាទនោះនៅជិតគ្នា គឺត្រង់ជ្រោងកំផែងប្រាសាទតាព្រហ្មខាងទិសអាគ្នេយ៍ នៅជិតគ្នានឹងជ្រុងកំផែងប្រាសាទបន្ទាយក្តីខាងទិសពាយ័ព្យ។


នៅពីក្រោយប្រាសាទ



# ប្រាសាទបន្ទាយក្តី

# ប្រាសាទបន្ទាយក្តី

ប្រាសាទនេះកាលដើមគេធ្វើដើម្បី ឧទ្ទិសដល់ព្រះពុទ្ធសាសនាខាងមហាយាន សាងដំណាលគ្នានឹងប្រាសាទតាព្រហ្មក្នុងរាជស្តេចឈ្មោះរាជេន្ទ្រវរម័ន ទី២ ប្រហែលជាដល់មកក្នុងរវាងពុទ្ធសករាជ ២០៥០ ប្រាសាទនោះក៏បាក់បែកជាច្រើន ទាំងក្បាច់ចម្លាក់នៅប្រាសាទនោះ ក៏របេះរបកជាច្រើនៗ



ចម្លាក់អប្សរា



រូបភាពខាងក្នុងប្រាសាទ



ខ្លោងទ្វារសាងអំពីថ្មភក់

ប្រាសាទនេះមានកំពែងព័ទ្ធជុំវិញ នៅកំផែងនេះមានទ្វារសម្រាប់ចេញចូលគ្រប់ទិសទាំង៤ តែទ្វារខាងកើតជាទ្វារធំនៅលើទ្វារនោះគេធ្វើជាប្រាសាទ មានកំពូលប្រដាប់ដោយមុខ៤ នៅត្រង់ជ្រុងទាំង៤ នៃប្រាសាទទ្វារនោះ មានរូបគ្រុឌមួយៗនៅគ្រប់ជ្រុង ឯទ្វារដែលចេញចូលបានសព្វថ្ងៃនេះ គឺទ្វារខាងលិចនិងខាងកើត កាលបើចូលទៅតាមទ្វារខាងកើត លុះចូលផុតទ្វារកំផែងនោះទៅ ត្រូវដើរទៅតាមផ្លូវដើង ដើរបន្តិចទៅក៏ដល់ទៅផ្លូវថ្ម ដែលមានរូបនាគជាប្រកាន់ដៃទាំងសងខាង ជាផ្លូវកាត់ស្រះចូលទៅដរាបដល់ទៅកំផែងទី ២ ដែលជាទីមានផ្ទៃជាប់គ្នារហូត ដល់ប្រាសាទកណ្តាលនៅកំផែងទី ២ នេះខាងកើតនិងខាងលិចមានទ្វារបីៗសម្រាប់ចេញចូល ខាងលើធ្វើជាកំពូល មានភាពជាប្រាសាទ តពីនោះទៅទៀតមានផ្លូវថ្មតភ្ជាប់គ្នាទៅនឹងប្រាសាទមានរាងទ្រវែង១ ប្រាសាទនេះមានទ្រង់សណ្ឋានដូចជាសាលាសព្វថ្ងៃនេះបាក់បែកអស់ហើយ នៅសល់តែសសរ និងជញ្ជាំង តពីនោះទៅទៀត មានផ្លូវថ្មប្រវែងចំនួន ៥ ម៉ែត្រ  តភ្ជាប់ទៅនឹង កំផែងទី ៣កំផែងនោះមានសណ្ឋានជារោងថែវព័ទ្ធជុំវិញ

ត្រង់កន្លែងទ្វាគេធ្វើជាប្រាសាទ មានកំពូលខ្ពស់ឡើង ហើយមានរោងថែវខ្វាត់ខ្វែងជាប់គ្នា និងប្រាសាទកណ្ដាលៗនោះ ធំនិងខ្ពស់ជាងប្រាសាទទាំង ៨ ដែលមាននៅដោយជុំវិញ។



នៅពីក្រោយប្រាសាទ

នៅក្នុងប្រាសាទបន្ទាយក្ដីនេះ ឃើញមានស្នាមកោសលុបព្រះពុទ្ធរូបដែលគេឆ្លាក់នៅសរសរ ឃើញទំនងបម្រុងនឹងធ្វើជារូបព្រាហ្មណ៍ត្រង់កន្លែងនោះខ្លះ ឃើញស្នាមកោតលុបបំបាត់ចោលខ្លះដែលកោសលុបព្រះពុទ្ធរូបនេះប្រហែលជាពួកអ្នកកាន់សាសនាព្រាហ្មណ៍ ដែលមកនៅគ្រប់គ្រងទីនោះជាចាងក្រោយនាំគ្នាបំផ្លាញអស់ទាំងព្រះពុទ្ធរូបនោះចេញ។



កំពែងព័ន្ធជុំវិញ

នៅកន្លែងខ្លះ ឃើញមានរូបចម្លាក់ ត្រង់រឿងព្រះផ្ចាញ់មារកន្លែងខ្លះ ឃើញរូបចម្លាក់ត្រង់រឿងកាលដែលគេបីព្រះសិទ្ធត្ថកាលនៅជាកុមារតូច ឲ្យទៅថ្វាយបង្គំអសិតតាបស ឬកាលទេវិលតាបស តែរូបម្នាស់ទាំងនេះ សុទ្ធតែសល់នៅពីការបំផ្លាញរបស់ពួកព្រាហ្មណ៍។

នៅកន្លែងខ្លះឃើញមានស្នាមវាយបំបាក់នឹងកាលលុបរូបខាងសាសនាព្រហ្មណ៍វិញក៏មាន ឯការបំផ្លាញរូបខាងសាសនាព្រហ្មណ៍នេះ ប្រហែលជាពួកអ្នកកាន់ព្រះពុទ្ធសាសនា ខាងហិនយានដែលមានមកក្នុងជាន់ក្រោយនាំគ្នាបំផ្លាញរូបខាងសាសនាព្រាហ្មណ៍នោះវិញ បានជាសព្វថ្ងៃនេះឃើញមានព្រះពុទ្ធរូបខាងលើហិនយានជាច្រើនព្រះអង្គនៅក្នុងប្រាសាទបន្ទាយក្ដីនោះបើកាលដែលចូលទៅក្នុងប្រាសាទនេះតាមទ្វារខាងលិចត្រូវចេញមកវិញតាមទ្វារខាងកើត កាលបើចេញផុតពីកំផែងខាងក្រៅ ហួសមកដល់លើផ្លូវថ្នល់បែកទៅខាងត្បូងត្រូវបង្វាសត្រង់ទៅខាងកើតតាមផ្លូវដើង ដើម្បីនឹងទៅមើលទីស្រះស្រង់។



រូបភាពខាងក្នុងប្រាសាទ



ច្រកចូលទៅប្រាសាទ



ចម្លាក់អប្សរា



នៅពីក្រោយប្រាសាទ



# ស្រះស្រង់

# ស្រះស្រង់

ស្រះស្រង់នេះបណ្ដោយពីខាងលិចទៅខាងកើត ចំនួន៧០០ម៉ែត្រ នៅចំពីខាងមុខប្រាសាទបន្ទាយក្ដី ហើយនៅជិតនឹងផ្លូវថ្នល់ នៅខាងលិចស្រះនេះ មានទីលានថ្ម១មានជណ្ដើរសម្រាប់ចុះទៅកាន់ស្រះ ហើយមានរូបនាគជាប្រកាន់ដៃផង បើអស្ដង្គតហើយ មើលទៅស្រះនោះ ឃើញល្អមើលណាស់។



ទិដ្ឋភាពស្រះស្រង់



ទេសភាពស្រស់បំព្រងព័ទ្ធជុំវិញ

នៅខាងត្បូងទីលានថ្មនោះ មានសាលាប្រក្បៀងស្អាតបាត គេទើបនឹងធ្វើ ដើម្បីប្រយោជន៍ដល់អស់អ្នកដំណើរដែលត្រូវការ នឹងចូលទៅឈប់សម្រាក ឬបរិភោគអាហារ។



នៅជុំវិញ

កាលបើផុតសេចក្ដីត្រូវការនឹងមើលទីស្រះស្រង់នោះហើយបើអស់អ្នកដំណើរមានពេលតិចត្រូវការនឹងវិលត្រឡប់ទៅវិញឆាប់ នោះចូរត្រឡប់ទៅវិញតាមផ្លូវថ្នល់ ដែលបែកទៅខាងត្បូងចុះព្រោះផ្លូវនោះវង់ធៀងទៅខាងលិចត្រង់ទៅលើអង្គរវត្ត បើទៅតាមផ្លូវនោះនៅចំនួនជាង២០០០ម៉ែត្រទៀត នឹងដល់ទៅអង្គរវត្ត នឹងក្រឡេកទៅឃើញប្រាសាទ១ឈ្មោះថាប្រាសាទក្រវាញនៅខាងឆ្វេងដៃ ជាប្រាសាទផ្សេកអំពីប្រាសាទឯទៀតៗ គួរតែឈប់ចូលទៅមើលមួយស្របក់សិន។



# ប្រាសាទក្រវាញ

# ប្រាសាទក្រវាញ

ដែលនឹងដើរពីថ្នល់ទៅកាន់ប្រាសាទក្រវាញនេះ ដើរទៅបានតែក្នុងរដូវខែប្រាំង លុះដល់រដូវខែវស្សា មានទឹកភ្លៀងច្រើននោះដើរទៅមិនបានទេ ព្រោះមានទឹកដក់នៅក្នុងស្រះដែលមាននៅជុំវិញប្រាសាទនោះ។



ទល់មុខប្រាសាទ

ប្រាសាទក្រវាញនេះគេសាងប្រហែលក្នុងរវាងពុទ្ធសករាជ ១៤៧០ ដើម្បីឧទ្ទិស្សថ្វាយដល់សាសនាព្រាហ្មណ៍ ប្រាសាទនោះមាន ៥ស្ថិតនៅជាជួរត្រង់ពីខាងជើងទៅខាងត្បូង តែសព្វថ្ងៃនេះសល់នៅតែ ៤ ព្រោះប្រាសាទ១ខាងជើងបាក់បែកអស់ហើយ ប្រាសាទទាំងនោះគេធ្វើដោយឥដ្ឋទាំងអស់វៀរលែងតែត្រង់កន្លែងទ្វារនិងស៊ុមទ្វារគេធ្វើដោយថ្ម ប្រាសាទទាំង៤ នោះសុទ្ធតែមានទ្វារតែមួយ ពីខាងកើត ប្រាសាទកណ្តាលធំនឹងខ្ពស់ជាងប្រាសាទទាំងសងខាង នៅសុំទ្វារប្រាសាទទាំង ៤នោះមានក្បាច់ចម្លាក់ល្អណាស់ នៅប្រាសាទកណ្តាលត្រង់ជញ្ជាំងឥដ្ឋខាងក្រៅសងខាងទ្វារ ឃើញចម្លាក់រម្ចេចរូបទ្វារបាល គឺអ្នករក្សាទ្វារ ខាងក្នុងប្រាសាទកណ្តាលត្រង់ជញ្ជាំងខាងត្បូង ឃើញចម្លាក់រម្ចេចរូបវិស្ណុមានដៃ ៤ជញ្ជាំងខាងជើងឃើញចម្លាក់រម្ចេចរូបវិស្ណុជិះលើគ្រុឌ ជញ្ជាំងខាងក្រោយឃើញរូបទេវតា ១ មានដៃ៨។

កាលបើមើលប្រាសាទក្រវាញនេះរួចហើយ ត្រូវទៅតាមផ្លូវថ្នល់ត្រង់ទៅអង្គរវត្តតាមសេចក្តីប្រាថ្នាចុះ។

បើអស់អ្នកដំណើរមានពេលច្រើន មិនប្រញាប់និងត្រឡប់វិញទេ កាលបើមើលទីស្រះស្រង់រួចហើយ ត្រូវទៅតាមផ្លូវថ្នល់បែកទៅខាងជើង ទៅតែបន្តិចទៅក៏ទៅជួបនឹងផ្លូវថ្នល់ ដែលមកពីខាងលិចត្រង់ទៅឯកើត ហើយត្រូវទៅតាមផ្លូវថ្នល់នោះតាមក្បែរមាត់ស្រះស្រង់ត្រង់ទៅខាងកើតដល់ទៅកន្លែងដែលបត់ទៅខាងជើងនៅត្រង់ជ្រុងផ្លូវបត់នោះមានប្រាសាទ១ឈ្មោះថាប្រាសាទប្រែរូប។



# ប្រាសាទប្រែរូប

# ប្រាសាទប្រែរូប

*ប្រាសាទប្រែរូបនេះ គេសាងប្រហែលក្នុងរវាងពុទ្ធសករាជ ១៥៥០ ដើម្បីឧទ្ទិស្សថ្វាយដល់សាសនាព្រាហ្មណ៍។*



*រូបភាពនៅប្រាសាទប្រែរូប*

*ប្រាសាទនេះមាន ៣ជាន់ក្នុងកំផែងទី១និងទី២សព្វថ្ងៃនេះ លំបាកចូលទៅណាស់ ព្រោះគេមិនទាន់រៀបចំធ្វើឲ្យស្អាតនៅឡើយ ដោយមានព្រៃដុះដាលពាសក្នុងកំផែងទាំង២ជាន់ឃើញមានប្រាសាទជាច្រើនក្នុងកំផែងទាំង២ជាន់នេះតែបាក់បែកជាច្រើន ត្រង់ជាន់កណ្តាលមានសណ្ឋានជាតួប្រាង្គណ៍ខ្ពស់ឡើង៣ថ្នាក់ មានជណ្តើរនៅល្អ សម្រាប់ឡើងទៅដរាបដល់ទីផ្ទៃខាងលើ នៅមាត់ជណ្តើរមួយៗ សុទ្ធតែមានរូបសត្វសីហនៅជាសងខាង នៅទីផ្ទៃខាងលើមានប្រាសាទ៥ គឺប្រាសាទ១នៅចំពាក់កណ្តាល មានទំហំធំនឹងខ្ពស់ជាងប្រាសាទទាំង៤ ដែលមានៅក្នុងជ្រុងទាំង៤ ប្រាសាទកណ្តាលនោះ មានជណ្តើរ៤សម្រាប់ឡើងគ្រប់ទិសទាំង ៤ ប្រាសាទទាំង ៥នោះមានទ្វារចូលទៅបានតែខាងទិសឯកើត ឯទិសទាំង៣ចូលទៅមិនបានទេព្រោះបិតជិតគ្រាន់តែមានទំនងជារាងទ្វារ ហើយមានក្បាច់ចម្លាក់យ៉ាងល្អនៅនឹងកន្លែងទ្វារទាំង៣ទិសនោះ។*

*ឯប្រាសាទទាំងអស់ក្នុងទីប្រាសាទប្រែរូបនេះ គេធ្វើដោយថ្មលាយនឹងឥដ្ឋ។ កាលបើចេញពីប្រាសាទប្រែរូបមក ត្រូវទៅតាមផ្លូវថ្នល់ត្រង់ទៅខាងជើងទៅចំនួន១៤០០ម៉ែត្រ ក៏នឹងឃើញប្រាសាទ១ទៀតនៅជាខាងលិចថ្នល់ ឈ្មោះថាប្រាសាទមេបុណ្យ ឯប្រាសាទមេបុណ្យនោះ មានទំនងបែបផែនដូចគ្នានឹងប្រាសាទប្រែរូបដែរ ប្លែកបន្តិចតែប្រាសាទមេបុណ្យនេះ មានរូបដំរីនៅត្រង់ជ្រុងខាងក្រោម។*

*លុះទៅតពីនោះទៀតក៏ដល់ទៅស្ពានថ្មី ដែលគេធ្វើដោយស៊ីម៉ង់នៅស្ទឹងសៀមរាប តពីស្ពាននោះតែបន្តិចទៅ ក៏នឹងឃើញប្រាសាទ ១នៅជាខាងកើតថ្នល់ ឈ្មោះថាប្រាសាទតាសោម។*



# ប្រាសាទតាសោម

# ប្រាសាទតាសោម

ប្រសាទតាសោមនេះ គេសាងប្រហែលក្នុងរវាងពុទ្ធសករាច១៧៥០ ដើម្បីឧទ្ទិស្សថ្វាយដល់ព្រះពុទ្ធសាសនាខាងមហាយាន។



រូបថតពីចម្ងាយ

ដែលនឹងចូលទៅកាន់ប្រាសាទនោះ សព្វថ្ងៃនេះចូលទៅបានតែតាមទ្វារខាងលិច ព្រោះទ្វារនោះនៅជិតផ្លូវថ្នល់។

ប្រាសាទនេះមានកំផែងព័ទ្ធជុំវិញ នៅកំផែងនោះមានទ្វារ៤គ្រប់ទិសទាំង៤ ទ្វារមួយៗ គេធ្វើមានកំពូលមានសណ្ឋានដូចជាប្រាសាទប្រដាប់ដោយមុខ ៤។

កាលបើចូលទៅតាមទ្វារខាងលិច ចូលផុតកំផែងទី១ ទៅហើយដើរបន្តិចទៅ ក៏ដល់ទៅផ្លូវថ្មដែលឆ្លងកាត់ស្រះ លុះដើរតាមផ្លូវនោះទៅក៏ដល់ទៅកំផែងទី២ ទៅផុតពីកំផែងទី២នោះទៅក៏ដល់ទៅកំផែងទី៣ កំផែងទី៣នេះ គេធ្វើមានសណ្ឋានជារោងថែវជុំវិញប្រាសាទកណ្ដាលនោះមានទំហំធំនឹងខ្ពស់ជាងប្រាសាទទាំង៨ ដែលមាននៅដោយជុំវិញ នៅខាងមុខប្រាសាទមានបណ្ណាល័យ២នៅសងខាងផ្លូវ។

ប្រាសាទនោះសព្វថ្ងៃនេះ លំបាកចូលទៅណាស់ព្រោះមានព្រៃនឹងដើមឈើធំៗ ដុះដាសពាសក្នុងប្រាសាទនោះដូចត្រង់ទ្វារខាងលិច មានដើមឈើធំ១ដើម ដុះពីខាងលើទ្វារហើយមានឫសដុះចាក់ពីកំពូលក្លោងទ្វារ ដរាបដល់ផែនដី ទាំងថ្មក៏ធ្លាក់រាត់រាយដេរដាសក្នុងទីនោះ គេមិនទាន់រៀបចំឲ្យស្អាតល្អនៅឡើយ។

កាលបើចេញពីប្រសាទតាសោមនេះមក ត្រូវទៅតាមផ្លូវថ្នល់ត្រង់ទៅខាងជើង ទៅតែបន្តិចទៅក៏បត់តាមផ្លូវថ្នល់ ត្រង់ទៅខាងលិចទៅ ចំនួនប្រហែលជា២គីឡូម៉ែត្រ នឹងឃើញផ្លូវដើង១នៅខាងជើងផ្លូវហើយដើរតាមផ្លូវនោះ កាត់ព្រៃបន្តិចទៅ និងឃើញប្រាសាទ១នៅក្នុងព្រៃឈ្មោះថាប្រាសាទក្រោលគោ។



# ប្រាសាទក្រោលគោ

# ប្រាសាទក្រោលគោ

ប្រាសាទក្រោលគោនេះជាប្រាសាទតូចណាស់ សព្វថ្ងៃនេះបាក់បែកជាច្រើនណាស់ហើយដែលនឹងចូលទៅមើលប្រាសាទនេះ ត្រូវចូលទៅតាមផ្លូវខាងកើត រូបចម្លាក់មាននៅនឹងប្រាសាទនោះ សង្កេតមើលទៅឃើញមានរូបចម្លាក់ ខាងព្រះពុទ្ធសាសនាខាងមហាយានក៏មាន ខាងសាសនាព្រាហ្មណ៍ក៏មាន។


ប្រាសាទក្រោលគោ


នៅពីក្រោយប្រាសាទ

កាលចេញពីប្រាសាទនេះមកវិញ ត្រូវទៅតាមផ្លូវថ្នល់ត្រង់ទៅខាងលិច ទៅតែបន្តិចទៅក៏នឹងឃើញថ្នល់ ១ផ្សេង នៅជាខាងឆ្វេងដៃ ដាច់ពីផ្លូវថ្នល់បែកត្រង់ទៅប្រាសាទនាគព័ន្ធ។


រូបចម្លាក់នៅប្រាសាទ



# ប្រាសាទនាគព័ន្ធ

# ប្រាសាទនាគព័ន្ធ

ប្រាសាទនេះគេធ្វើដើម្បីឧទ្ទិស្សថ្វាយដល់អវលោកិតេស្វរបានជាដឹងដូច្នេះ ដឹងដោយការស្នាដៃរបស់អ្នកប្រាជ្ញបារាំងម្នាក់ ឈ្មោះ ល្វីហ្វីណូត៍ លោកនេះបានទៅពិនិត្យសង្កេតមើលនៅទីនោះ ហើយ


រូបចម្លាក់នៅក្នុងប្រាសាទ


រូបចម្លាក់នៅក្នុងប្រាសាទ

បានដឹងប្រាកដថា ជាគេធ្វើដើម្បីឧទ្ទិស្សដល់ព្រះអវលោកិតេស្វរ ដោយមានគ្រឿងតិកតាង ល្មមឲ្យសង្កេតទៅជឿបាន ដោយឥតមានសង្ស័យ។

ប្រាសាទនោះមានកំផែងព័ទ្ធជុំវិញ នៅក្នុងកំផែងនោះមានស្រះធំ៤ជ្រុង១នៅចំពាក់កណ្តាល ហើយមានស្រះតូចៗនៅគ្រប់ទិសទាំង៤ស្រះទាំង៥នោះសុទ្ធតែមានថ្មគេរៀប់ជាថ្នាក់ជាជណ្តើរជុំវិញតាំងពីមាត់ស្រះសម្រាប់ចុះទៅក្នុងស្រះ ត្រង់កណ្តាលស្រះធំ មានទីផ្ទៃដីរាលមូលខ្ពស់ឡើង មានសណ្ឋានដូចជាកោះ ហើយមានថ្មគេរៀបជាថ្នាក់ៗ ជាជណ្តើរសម្រាប់ចុះទៅក្នុងស្រះ ឯប្រាសាទដែលនិយាយពីខាងដើមនោះ ស្ថិតនៅចំពីខាងលើទីដីកណ្តាលស្រះធំនោះឯង ហើយមានដើមត្រាង១ដើម ដុះចំពីខាងលើប្រាសាទ មានឫសដុះព័ទ្ធព័ន្ធប្រាសាទនោះដោយជុំវិញ មែកត្រាងនោះដែលធ្លាក់សំយោគគ្រប ពីលើមានសណ្ឋានដូចជាឆ័ត្របាំងពីខាងលើ។

ទីផ្ទៃដីដែលទ្រប្រាសាទនោះមានសណ្ឋានដូចជាស្រទាប់ផ្កាឈូក ត្រង់កន្លែងខាងលើជណ្តើរ ទីខាងក្រោមមានរូបនាគ២កន្ទុយចាក់ទៅខាងលិចព័ទ្ធព័ន្ធគ្នាត្របាញ់ត្រង់ឡើង ដូចកន្ទុយនាគតែ ១ក្បាលមកខាងកើតព្រោះហេតុនេះបានជាគេហៅថាប្រាសាទនាគព័ន្ធ។

នៅក្នុងស្រះនោះ ត្រង់ទីជុំវិញប្រាសាទ កាលពីដើមមានទឹកដក់ជានិច្ច ទឹកនោះគេច្រើនរាប់អានដោយសំគាល់ថាជាទឹកមានអានុភាពពូកែណាស់។

នៅប្រាសាទនោះ ត្រង់ទីខាងក្រោមឃើញមានថ្មឆ្លាក់ ចាផ្កាឈូកទ្រ ត្រង់ទីជញ្ជាំងខាងលើទ្វារខាងកើតនឹងខាងជើង មិនមានឫសឈើព័ទ្ធព័ន្ធឡើយ ម៉្លោះហើយគេមើលទៅឃើញក្បាច់រម្ទេច ត្រង់រឿងកាលព្រះសិទ្ធត្ថកាត់ព្រះកេសា ទៀបឆ្នេរស្ទឹងអនោមានទី នឹងកាលដែលអាមាត្យឈ្មោះឆន្ន នាំសេះកណ្ឋកត្រឡប់ទៅព្រះរាជវង់វិញ ត្រង់កន្លែងទ្វារនៅជញ្ជាំងខាងជើងនឹងខាងលិច ឃើញមានរូបអវលោកកិតេស្វរ ព្រមទាំងគ្រឿងប្រដាប់របស់អវលោកិតេស្វរ នោះផងត្រង់កន្លែងទ្វារនៅជញ្ជាំងខាងត្បូងឃើញមានរូបអរលោកិតេស្វរ ហើយឃើញរូបព្រះអាទិត្យនឹងព្រះចន្ទ កំពុងតែនមស្សការ ទៅអវលោកិតេស្វរនោះ ឯក្បាច់ចម្លាក់ទាំងនោះ សុទ្ធតែក្បាច់ចម្លាក់យ៉ាងល្អ។

នៅក្នុងស្រះត្រង់កន្លែងជិតជើងជណ្តើរខាងកើត គេជីកដីទៅឃើញផែនថ្ម ១ ថ្មនោះគេឆ្លាក់ជារូបមនុស្សមានចំនួនច្រើនតោងរូបសេះ រូបទាំងនេះតាមលោក ល្វីហ្វីណូត យល់ថាជារូបគេធ្វើចំពោះត្រង់រឿងកាលព្រះអបលោកិតេស្វរ ដំណែងខ្លួនជាសេះពលាហក ទៅស្រង់អស់ទាំងមនុស្ស ដែលលង់ទឹកនៅនាកោះរក្សសី ឯនៅក្នុងស្រុកខ្មែរគេអាចដឹងបាន ថាតែអវលោកិតេស្វរ ដំណែងខ្លួនជាសេះ

ពលាហក ព្រោះនៅវិមានអាកាសមានសិលាចារិកជាភាសាសំស្ក្រឹត និយាយថាលោកកេសូរដំណែងខ្លួនជាសេះពលាហក ផែនថ្មដែលគេឆ្លាក់ ជារូបមនុស្សតោងសេះនោះ ជាចម្លាក់ល្អណាស់ គួរនឹងរាប់ទុកជាចម្លាក់យ៉ាងល្អសំខាន់១យ៉ាង។

នៅស្រះធំមានកន្លែង៤ជាប្រហោងតូចៗ សម្រាប់ចាក់ទឹកបង្ហូរទៅក្នុងស្រះតូចទាំង៤ ត្រង់កន្លែងប្រហោងនោះគេឆ្លាក់ថ្មធ្វើឲ្យមានសណ្ឋានដូចផ្កាឈូក កាលបើចាក់ទឹកទៅ ទឹកនឹងហូរធ្លាក់ចុះទៅកាន់ស្រះទាំង៤ តាមថ្មដែលគេធ្វើឲ្យមានសណ្ឋានជាក្បាលសត្វសីហ ខាងលិចជាក្បាលសត្វតែមិនប្រាកដជាសត្វអ្វីខាងជើងជាក្បាលដំរី នៅត្រង់កន្លែងមួយៗនោះ មានប្រាសាទតូចៗគ្របពីលើ។

នៅនឹងប្រាសាទតូចៗ ទាំង៤នោះកន្លែងខ្លះឃើញមានរូបចម្លាក់អវលោកិតេស្វរ ដែលកំពុងធ្វើសេចក្ដីសង្គ្រោះ ដល់មនុស្ស ឲ្យបានរួចពីសេចក្ដីទុក្ខលំបាក មានជម្ងឺជម្កាត់ជាដើមកន្លែងខ្លះឃើញមានរូបចម្លាក់អវលោកិតេស្វរ ហើយឃើញមានរូបមនុស្សកំពុងតែនមស្សការ កន្លែងខ្លះឃើញតែលិង្គព្រះឥសូរ ប៉ុន្តែសង្កេតមើលទៅឃើញមានស្នាមកោសលុបត្រង់កន្លែងនោះនេះប្រហែលជាពួកអ្នកកាន់សាសនាព្រាហ្មណ៍នាំគ្នាកោសលុបរូបអវលោកិតេស្វរចេញ ហើយធ្វើលិង្គព្រះឥសូរដាក់ត្រង់កន្លែងនោះវិញ។

កាលបើចេញពីប្រាសាទនាគព័ន្ធមកវិញ ត្រូវចេញមកតាមផ្លូវដដែល លុះដល់មកផ្លូវថ្នល់ ត្រូវទៅតាមផ្លូវនោះត្រង់ទៅខាងលិច ទៅតាមផ្លូវនោះទៅ នឹងឃើញផ្លូវជើង ១ នៅជាខាងត្បូងផ្លូវ បែកចូលទៅកាន់ទ្វារកំផែងខាងជើង នៃប្រាសាទព្រះខ័ន។



រូបភាពនៅក្នុងប្រាសាទ



ផ្លូវទៅកាន់ប្រាសាទ



ចំហៀងប្រាសាទ



# ប្រាសាទព្រះខ័ន

# ប្រាសាទព្រះខ័ន

ប្រាសាទព្រះខ័ននេះ មានស្រះព័ទ្ធជុំវិញពីខាងក្រៅ តរពីស្រះទៅមានកំផែងព័ទ្ធជុំវិញទៀត កំផែងនោះបណ្តោយ ៨០០ម៉ែត្រ ទទឹង៧២០ម៉ែត្រ នៅក្នុងកំផែងនោះមានប្រាសាទជាច្រើន ជាទីធំណាស់ដែរ ប្រហែលជាកាលពីដើមទីព្រះខ័ននេះជាទីវ៉ែ ១ គេសាងក្នុងរាជស្តេចឈ្មោះជយវរម័នទី២ ប្រហែលក្នុងព្រះពុទ្ធសករាជជាង១៣៥០។



ប្លង់នៃប្រាសាទព្រះខ័ន



សំណង់មន្ទីរមានសរសរមូលៗនៅប្រាសាទព្រះខ័ន

តាមដែលគេបានទៅពិនិត្យមើល អស់ទាំងរូបចម្លាក់នឹងសិលាចារិកនៅទីប្រាសាទនោះ គេអាចស្មានបានថាទីប្រាសាទនេះ កាលពីដើមជាទីមានសាសនាព្រាហ្មណ៍ ព្រោះគេឃើញរូពចម្លាក់ជារូបវិស្ណុ រូបសិវនឹងរឿងរាមាយណ។ល។

ទីប្រាសាទព្រះខ័នសព្វថ្ងៃនេះ គេមិនអាចនឹងសង្កេតពិនិត្យមើលហើយកំណត់ឲ្យប្រាកដបានឡើង ព្រោះប្រាសាទក្នុងទីនោះបាក់បែកជាច្រើនណាស់ ហើយព្រៃក៏ដុះពាសពេញដេរដាសក្នុងទីនោះផង។

ដែលនឹងចូលទៅកាន់ទ្វារកំផែងខាងក្រៅនោះ មានផ្លូវ៤ឆ្លងកាត់ស្រះចូលទៅគ្រប់ទិសទាំង ៤ តែផ្លូវទៅស្រួលសព្វថ្ងៃនេះគឺផ្លូវខាងលិចនឹងខាងជើង ព្រោះផ្លូវទាំង២ ទិសនេះជាប់ពីផ្លូវថ្នល់ទៅដរាបដល់កំផែងខាងក្រៅនោះ គែធ្វើដោយថ្មបាយក្រៀម រៀរលែងតែត្រង់កន្លែងទ្វារគេធ្វើដោយថ្មពណ៌ប្រផេះ។

នៅកំផែងខាងក្រៅនោះ មានទ្វារសម្រាប់ចេញចូលគ្រប់ទិសទាំង៤ ក្នុងទិសមួយៗ មានទ្វារបី នៅទ្វារទាំង ៤ទិសនោះគេធ្វើឲ្យមានសណ្ឋានជាតួប្រាសាទទាំងអស់ ត្រង់ទីសងខាងទ្វារ គេធ្វើជារូបគ្រុឌចាប់នាគ ជារូបធំៗធ្វើដោយថ្មដាក់ភ្ជាប់ទៅនឹងកំផែងនោះម្ខាងៗរូបគ្រុឌមួយ។

កាលបើចូលផុតពីកំផែងខាងក្រៅទៅ ហើយដើរចូលទៅនឹងឃើញកំផែងនឹងរោងថែវខ្វាត់ខ្វែងជាច្រើនទាំងប្រាសាទក៏ឃើញមានច្រើន នៅប្រាសាទខ្លះឃើញមានចម្លាក់រម្មេចរូបល្ខោននៅត្រង់មេទ្វារប្រាសាទទាំងអស់នោះ សុទ្ធតែមានក្បាច់ចម្លាក់យ៉ាងល្អ។

ក្នុងទីប្រាសាទព្រះខ័ននេះ យើងមិនអាចនឹងរៀបរាប់ឲ្យហូរហែរសព្វគ្រប់បានឡើយ ព្រោះប្រាសាទ់ក្នុងទីនោះទាំងអស់បាក់បែកជាច្រើនណាស់ ហើយដុំថ្មក៏ធ្លាក់រាត់រាយដេរដាសប្រគរលើគ្នាលំបាកនឹងដើរចូលទៅណាស់ ដើរជាន់តែលើគំនរថ្មទាំងព្រៃក៏ដុះស្កុកស្កកស្កាញចង្អៀត ព្រោះគេមិនទាន់បានរៀបចំទីនោះឲ្យស្អាតល្អនៅឡើយ ហេតុនេះបានជាយើងមិនអាចនិងដើរចូលទៅពិនិត្យយល់សព្វកន្លែងបាន។

បើកាលដែលចូលទៅតាមទ្វាខាងជើង ដល់ត្រឡប់មកវិញ ត្រូវចេញមកតាមទ្វារខាងលិច លុះមកដលផ្លូវថ្នល់ខាងលិច ត្រូវទៅតាមផ្លូវនោះ រហូតមកដល់ទ្វាយអង្គរធំខាងជើងហើយទៅតាមផ្លូវនោះ

កាត់ទីអង្គរធំត្រង់ទៅខាងត្បូងទៅ នឹងដល់ទៅមុខទីព្រះលានស្តេច នឹងដល់ទីមុខបាយ័ន ហើយកាត់ទៅតាមផ្លូវត្រង់ទៅខាងត្បូង ដរាបដល់ចេញពីទ្វារអង្គរធំខាងត្បូង លុះទៅតាមផ្លូវនោះទៅ ដល់ទៅភ្នំបាក់ខែង ដល់ទៅផ្លូវថ្មីដែលបត់ចូលទៅអង្គរវត្ត ដល់ទៅផ្ទះសំណាក់ដរាដល់សៀមរាប។

បើអស់អ្នកដំណើរមានប្រាថ្នាចង់មលទ្រង់ទ្រាយអង្គរវត្តពីខាងកើតក៏ចូលទៅតាមផ្លូវថ្មល់១ដែលកាត់ត្រង់ទៅខាងកើត នឹងបានឃើញទ្រង់ទ្រាយអង្គរវត្ត ហើយនឹងបានឃើញផ្កាឈូកដែលនៅក្នុងស្រះល្អមើលណាស់ រួចហើយសឹមត្រឡប់ទៅសៀមរាបតាមសេចក្តីប្រាថ្នាចុះ។



នៅប្រាសាទព្រះខ័ន



នៅប្រាសាទព្រះខ័ន


8 847100 740199 >
MAGA
MAGAZINE